ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
THE MESSENGER

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២ | សម្រាប់ខែ មីនា ឆ្នាំ ២០២០ | តម្លៃលក់ ១០០០រៀល | លេខ #១២៥




## ចូរអរព្រះគុណ, ព្រះជាម្ចាស់ គ្រប់ពេលវេលា!

ទំព័រ-៨

■ ការីតាសកម្ពុជាលើកកម្ពស់ការអប់រំសម្រាប់ជនជាតិដើមភាគតិច



ទំព័រ-៤

■ យុវជនរៀនធ្វើជាអ្នកកសាងសន្តិភាពដោយជំនឿ និងសកម្មភាព

ទំព័រ-៧

■ ព្រះសហគមន៍បាត់ដំបងរំឭកខួប២៣០ឆ្នាំ

ទំព័រ-១៣



## ពលរដ្ឋជិតដាមនឹងការរីកសាយភាយនៃ
# មេរោគកូវីដ-១៩

ទំព័រ-១០-១១



## វិចារណកថា

# កម្ពុជានៅក្នុងសង្គមមនុស្សធម៌

*ដោយ៖ លី សុវណ្ណា*



ថ្មីៗនេះ ពិភពលោកស្ថិតក្នុងភាពជ្រួលច្របល់ដោយសារមេរោគថ្មីមួយបានកើតឡើងនៅក្នុងប្រទេសចិន ក្នុងទីក្រុងវូហាន ធ្វើឲ្យមនុស្សស្លាប់ចំនួន២០០៩នាក់ និងមានអ្នកផ្ទុកមេរោគនេះចំនួន៧៤១៨៥នាក់។ នេះបើយោងតាមទិន្នន័យរបស់ក្រសួងសុខាភិបាលរបស់ចិនកាលពីថ្ងៃទី១៩ ខែកុម្ភៈ។

ដោយសារជំងឺនេះ នាវាទេសចរណ៍ដ៏ធំមួយរបស់អន្តរជាតិគ្មានអ្នកទទួលស្វាគមន៍ និងគ្មានទីសំចត។ ប៉ុន្តែកម្ពុជា ដែលជាប្រទេសតូចបានផ្តល់ទីកន្លែង និងបដិសណ្ឋារកិច្ចដល់អ្នកទេសចរជាង២២០០នាក់ ហើយទទួលបានការគាំទ្រ និងការគោរពពីអន្តរជាតិ។ ទន្ទឹមនឹងនេះ ក៏មានប្រជាជនកម្ពុជាខ្លះមិនពេញចិត្តនិងចោទថា រដ្ឋាភិបាលនាំជំងឺចូលក្នុងប្រទេសរបស់ខ្លួន។

គំនិតរបស់ប្រជាជនពិតជាមិនខុសទេ តែសូមគិតឡើងវិញអំពីចំណុចផ្សេងទៀតក្រៅពីភាពភ័យខ្លាច។ នាវាវេស្ទ័រដាមត្រូវបានប្រទេសចំនួន៤ និងដែនកោះចំនួន២បានបដិសេធមិនទទួលពួកគេ។ មនុស្សជាង២២០០នាក់ត្រូវការជំនួយផ្នែកមនុស្សធម៌ ដើម្បីឲ្យពួកគាត់អាចបន្តរស់រាន។ វាជាសិទ្ធិមនុស្សក្នុងមាត្រាដំបូងបំផុត។ ប្រសិនបើយើងមើលរំលងអំពីចំណុចនេះ ហើយគិតកង្វល់អំពីភាពភ័យខ្លាចនៃមេរោគកូរ៉ូណា (Covid 19) នេះតែម្យ៉ាង នោះភាពជាមនុស្សនឹងត្រូវបាត់បង់។

ក្នុងគម្ពីរ ព្រះយេស៊ូបានមានបន្ទូលអំពីចៀមមួយក្បាលដែលវង្វេងបាត់។ ក្នុងនាមជាគង្វាល អ្នកឃ្វាលសត្វបានដើររកចៀមតែមួយក្បាល ហើយទុក៩៩ក្បាលទៀតចោល។ អត្ថបទនេះ បានបញ្ជាក់ច្បាស់ថា ព្រះជាម្ចាស់មិនបានបោះបង់ចោលមនុស្សអស់សង្ឃឹមឡើយ ព្រះអង្គចង់នៅជាមួយគេដល់ទីបញ្ចប់។ ក្នុងនាមជាគ្រីស្តបរិស័ទ អត្ថបទនេះ ជួយយើងដើម្បីរិះគិតអំពីមនុស្សជាង២២០០នាក់នេះ។

ជាការពិត មនុស្សណាក៏ខ្លាចឆ្លងជំងឺនេះដែរ។ ជីវិតគឺមានតែមួយគ្មានពីរទេ ប៉ុន្តែចូរមានជំនឿលើព្រះជាម្ចាស់ ព្រះអង្គនឹងជួយយើងដើម្បីស្វែងរកមធ្យោបាយដោះស្រាយវិបត្តិសកលលោកមួយនេះ។ មុននឹងទទួលបានដំណឹងល្អនេះ ក្នុងនាមជាមនុស្សយើងត្រូវចេះរំលែកសេចក្តីសុខសាន្តដល់គ្នា ជួយគ្នាទៅវិញទៅមក និងផ្តល់សេចក្តីសង្ឃឹមដល់គ្នាផង។

ការអនុញ្ញាតឲ្យនាវាវេស្ទ័រដាម សំចតនៅកំពង់ផែអន្តរជាតិខេត្តព្រះសីហនុនេះ រដ្ឋាភិបាលក៏ធ្វើដោយយកចិត្តទុកដាក់និងមានកិច្ចការពាររួចស្រេចដែរ គឺអស់អ្នកទាំងប៉ុន្មាននៅលើនាវាក៏ត្រូវបានពិនិត្យសំណាកយ៉ាងយកចិត្តទុកដាក់ ដោយមានទាំងអ្នកវេជ្ជសាស្ត្រអន្តរជាតិនិងអ្នកការទូតតាមដាន និងត្រួតពិនិត្យរួមគ្នាផង។ បច្ចុប្បន្ន កម្ពុជានៅតែតាមដាន ជាមួយក្រុមភ្ញៀវទាំងប៉ុន្មានដែលចុះចេញពីកប៉ាល់មួយនេះ ហើយត្រៀមចេញទៅកាន់ប្រទេសទីទៃ ដើម្បីទៅប្រទេសរបស់ពួកគេវិញ។ លទ្ធផលនៃសំណាក គឺគ្មាននរណាម្នាក់មានផ្ទុកមេរោគរលាកសួតប្រភេទថ្មីនៃមេរោគCovid 19 នោះទេ។

ចំពោះស្ត្រីជាតិអាមេរិក ជាអ្នកទេសចរនៅលើនាវានោះ ត្រូវបានប្រទេសម៉ាឡេស៊ីរកឃើញថា មានផ្ទុកមេរោគ Covid 19 កាលពីថ្ងៃទី១៥ ខែកុម្ភៈ កន្លងទៅ ប៉ុន្តែករណីផ្សេងៗទៀតចំពោះស្ត្រីម្នាក់នេះ នៅមិនទាន់មានព័ត៌មានណាមួយបញ្ជាក់ច្បាស់លាស់នោះទេ ព្រោះស្ថិតក្នុងការតាមដាន បើទោះបីមានការបញ្ជាក់ពីអាជ្ញាធរប្រទេសម៉ាឡេស៊ីថា ការធ្វើចំនួនពីរលើកគឺ លទ្ធផលវិជ្ជមានដូចគ្នា។ ប៉ុន្តែនាថ្ងៃសុក្រទី២១ ខែកុម្ភៈ ឧបនាយករដ្ឋមន្ត្រីម៉ាឡេស៊ី បានប្រកាសថា ស្ត្រីអ្នកទេសចរសញ្ជាតិអាមេរិកមិនមានមេរោគ Covid 19 ទៀតនោះទេ។

ទោះបីជាមានរឿងនេះកើតឡើង ប៉ុន្តែភាពជាមនុស្សធម៌សូមកុំបោះបង់។ គ្រីស្តបរិស័ទយើងអាចមើលឃើញពីសក្ខីកម្ម ជាច្រើនរបស់សន្តបុគ្គល តួយ៉ាងសន្តដាមីញាំងនៅហាណូលូលូ នៃរាជាណាចក្រហាវ៉ៃ។ ក្នុងសម័យដែលមានជំងឺឃ្លង់ គាត់បានបំពេញបេសកកម្មប្រកាសដំណឹងល្អនៅទីនោះ និងរស់នៅជាមួយប្រជាជនកើតជំងឺឃ្លង់ ដែលបាក់ទឹកចិត្ត និងអស់សង្ឃឹម។ ប៉ុន្តែផលផ្លែនៃសេចក្តីស្រឡាញ់របស់គាត់ បានបង្កើតសហគមន៍មួយប្រកបដោយចិត្តអង់អាចនិងគោរពស្រឡាញ់ព្រះជាម្ចាស់។

សន្តី តេរាសានៃក្រុងគុលកូថាប្រទេសឥណ្ឌា បានខិតខំជំនះគ្រប់យ៉ាងចាកចេញពីអារាម ដែលពោរពេញដោយសេចក្តីសុខ ទៅបម្រើបងប្អូននៅតាមដងផ្លូវ ដែលជិតស្លាប់ ដែលមានជំងឺធ្ងន់ អ្នកក្រីក្រដែលគេមើលងាយ រហូតដល់ជីវិតចុងក្រោយ ហើយស្មារតីនេះនៅតែបន្ត និងបានសាយភាយ កិច្ចការនេះទៅក្រៅប្រទេសឥណ្ឌា។ ហើយនៅកម្ពុជាក៏មានវត្តមានក្រុម ដែលជាសមាជិក នៃក្រុមគ្រួសារសន្តីតេរេសាផងដែរ។

ក្នុងឆ្នាំ២០១៨ ក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ មានប្រសាសន៍ថា សិទ្ធិនៃការរស់រានជាអាទិភាព ទោះបីវាត្រូវបានប្រឆាំងយ៉ាងមាំក៏ដោយ។ សម្តេចប៉ាបមានប្រសាសន៍ទៀតថា យើងម្នាក់ៗ ជាពិសេសគ្រីស្តបរិស័ទ ត្រូវបានចោទសួរ ដើម្បីឆ្លើយតបដោយក្លាហាន និងការប្តេជ្ញាចិត្តជាមួយសេចក្តីគោរព។ សម្រាប់អ្នកទាំងនោះ «នេះជារឿងចាំបាច់សម្រាប់យុត្តិធម៌ និងសាមគ្គីភាព» ជាអត្ថន័យពិសេសមួយ។ សម្តេចប៉ាបក៏បានជម្រុញឲ្យម្នាក់ៗចេះ «រំកិលខ្លួនដោយមេត្តាករុណា» នៅពេលមើលឃើញអ្នកដទៃ ដែលងាយរងគ្រោះជាង ហើយ«ខិតខំប្រឹងប្រែងយ៉ាងពិតប្រាកដ ដើម្បីកាត់បន្ថយទុក្ខលំបាករបស់ពួកគេ»។

នៅក្នុងពេលថ្មីៗនេះ លោកអភិបាលអូលីវីយេ តែងជំរុញគ្រីស្តបរិស័ទទូទៅ យុវជនយុវនារី បគ្គលិកនៃអង្គការក្រៅរដ្ឋាភិបាល ដែលបម្រើសង្គម ត្រូវធ្វើជាអ្នកកសាងសន្តិភាព ដោយយកមូលដ្ឋានគ្រឹះជាសំខាន់លើក សេចក្តីសុខសាន្តសុភមង្គលតាមរបៀបព្រះយេស៊ូ គឺយើងស្វែងរកសេចក្តីសុខ ព្រមទាំងចែករំលែក និងណែនាំឲ្យបងប្អូនជុំវិញខ្លួនមានសេចក្តីសុខ សុភមង្គលយ៉ាងពិតប្រាកដ។ បម្រើបងប្អូនដោយចិត្តស្រលាញ់។

សរុបមកសូមបងប្អូនរួមគ្នាជាធ្លុងមួយ ទាំងកាយចិត្តរួមជាមួយរាជរដ្ឋាភិបាលគាំទ្រ ចំពោះការឆ្លើយតបប្រកបដោយវិជ្ជមាន លើកិច្ចការមនុស្សធម៌ និងមេត្តាករុណា ដែលរដ្ឋាភិបាលបានអនុវត្តន៍ ចំពោះបងប្អូនរាប់ពាន់នាក់នៅលើនាវាយក្ស ស្របពេលដែលមនុស្សគ្រប់គ្នាមានការភ័យខ្លាចរហូតបាត់ស្មារតីនៃកិច្ចការមនុស្សធម៌ ចំពោះមនុស្សជាតិដូចគ្នា៕



*នាវាទេសចរដែលផ្ទុកមនុស្សជាង២២០០នាក់បានចូលចតក្នុងកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ។ រូបភាព៖ ហ្វេសប៊ុក*

Formation, Dailouge, Cooperation
**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

**ចាងហ្វាង : លោក លី សុវណ្ណា**
**សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩**
**ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ**
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh





# ច្បាប់ស្តីពីសមាគម-អង្គការ មិនមែនរដ្ឋាភិបាលកំពុងតែស្ថិតនៅក្នុងការធ្វើវិសោធនកម្ម

*ដោយ៖ អរិយបុត្រ*

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅពេលនេះកំពុងតែស្ថិតនៅក្នុងដំណើរការធ្វើវិសោធនកម្ម ដើម្បីសុក្រិត្យភាព និងប្រសិទ្ធភាពនៅក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃគោលការណ៍ លទ្ធិប្រជាធិបតេយ្យ និងគោលដៅនៃការអភិវឌ្ឍ ។ នេះបើតាមការបញ្ជាក់របស់មន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ។

លោក ប៊ុន ហ៊ុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងថា មកដល់ពេលនេះ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំពុងតែស្ថិតនៅក្នុងដំណើរការនៃការពិភាក្សា។

លោកបានឲ្យដឹងថា ការងារបន្តពិភាក្សាលើខ្លឹមសារវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលគឺ ដើម្បីធ្វើយ៉ាងណាឲ្យច្បាប់នេះកាន់តែមានតម្លៃខ្ពស់បន្ថែមទៀត ជាពិសេសធ្វើយ៉ាងណាឲ្យការអនុវត្តកាន់តែមានប្រសិទ្ធភាព។

លោកបានបន្តថា ក្រុមការងារអន្តរក្រសួងនឹងបន្តពិភាក្សាជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យរកអ្វីដែលជាចំណុចមិនសមស្របសម្រាប់អនុវត្តក្នុងស្ថានភាពបច្ចុប្បន្ន ដែលតម្រូវឱ្យធ្វើវិសោធនកម្មឡើងវិញ ហើយបានស្នើឲ្យអង្គការសង្គមស៊ីវិល ព្រមទាំងដៃគូពាក់ព័ន្ធទាំងអស់ចូលរួមជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាល ឲ្យអស់ពីលទ្ធភាព ដើម្បីធ្វើយ៉ាងណាឲ្យរាល់កិច្ចពិភាក្សាទាំងអស់ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃអាចស្វែងរកចំនុចខ្លាំង និងចំនុចខ្សោយ ហើយប្រមូលបានធាតុចូលសំខាន់ៗក្នុងការធ្វើវិសោធនកម្មច្បាប់មួយនេះឲ្យមានភាពពេញលេញដែលអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ហើយស្របតាមការអនុវត្តការងារជាក់ស្តែងផងដែរ។



រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ✓

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**កិច្ចប្រជុំបន្តដើម្បីពិគ្រោះយោបល់លើសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ព្រមទាំងសាធារណៈជនជាតិ និងអន្តរជាតិជ្រាបថា ក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល នឹងបន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយតំណាងអង្គការសង្គមស៊ីវិល ដើម្បីពិនិត្យ និងពិភាក្សាលើខ្លឹមសារសំខាន់ៗ ពាក់ព័ន្ធនឹងការស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលរបស់អង្គការសង្គមស៊ីវិល។

ចំពោះកិច្ចប្រជុំបន្តដើម្បីពិគ្រោះយោបល់នេះ ត្រូវរៀបចំឡើងនៅថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង៨:៣០ នាទីព្រឹក នៅសាលប្រជុំ "អគារទ" ទីស្តីការក្រសួងមហាផ្ទៃ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ព្រមទាំងសាធារណៈជនជាតិ និងអន្តរជាតិជ្រាបជាព័ត៌មាន។

ថ្ងៃ...........ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០២០
ក្រសួងមហាផ្ទៃ

e-mail: moi@interior.gov.kh web: www.interior.gov.kh

មកដល់ខែ កុម្ភៈនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងមន្ត្រីអន្តរក្រសួងក្រោមការដឹកនាំដោយក្រសួងមហាផ្ទៃបានជួបគ្នាយ៉ាងហោចណាស់ ៤លើកមកហើយ ដោយកិច្ចប្រជុំពិគ្រោះយោបល់លើខ្លឹមសារនៃការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នេះមានការចូលរួមពីសមាជិកក្រុមការងារអន្តរក្រសួងរបស់រាជរដ្ឋាភិបាល អង្គទូតនានា ដៃគូអភិវឌ្ឍ ព្រមទាំងអង្គការសង្គមស៊ីវិល និងអង្គភាពស្ថាប័នពាក់ព័ន្ធជាច្រើនផងដែរ។

លោក ហ្វា សាលី ប្រធានសម្ព័ន្ធសហជីពជាតិកម្ពុជា បានឲ្យដឹងកាលពីថ្ងៃទី ០៦ ខែកុម្ភៈថា ក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សេរីភាពសហជីព ហាក់មានការរិតត្បិតខ្លះ ដូច្នេះ លោកសង្ឃឹមថា ការធ្វើវិសោធនកម្មនេះនឹងកាន់តែឆ្លើយតប និងបើកទូលាយ សិទ្ធិឲ្យសហជីពធ្វើសកម្មភាពកាន់តែមានសេរីភាពថែមទៀត ដើម្បីការពារ និងលើកកំពស់សិទ្ធិកម្មករ និងកម្មការិនីនៅកម្ពុជា។

កាលពីពេលថ្មីៗកន្លងទៅនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃក៏បានធ្វើការអំពាវនាវទៅដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល បន្តអនុវត្តសកម្មភាពរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ និងបទដ្ឋានពាក់ព័ន្ធ ចៀសវាងជាដាច់ខាតនូវសកម្មភាពណាដែលរំលោភច្បាប់ ។

សម្តេចបានមានប្រសាសន៍ថា៖ «ក្រសួងមិនបានរិតត្បិតការធ្វើសកម្មភាពរបស់សង្គមស៊ីវិលទេក្នុងឆ្នាំ២០១៩ ហើយអាជ្ញាធរមូលដ្ឋានហាក់មានការយល់ដឹងច្រើន និងផ្តល់កិច្ចសហការបានទូលំទូលាយច្រើន។

សម្តេចក៏បានបង្ហាញក្តីចម្ងល់ ចំពោះសង្គមស៊ីវិលខ្លះដែលមានជំនាញតែខាងបូកសរុបបញ្ហាយកទៅផ្សព្វផ្សាយ ប៉ុន្តែមិនបានផ្តល់ព័ត៌មានអំពីបញ្ហាទាំងនោះមកក្រុមការងារក្រសួងមហាផ្ទៃ ដើម្បីសហការដោះស្រាយឡើយ។ សម្តេចចាត់ទុកថានេះគឺជាការលាក់ព័ត៌មាន ហើយទំនាក់ទំនងនេះវាហាក់ដូចជាមិនមានតម្លាភាព និងផ្ទុយពីការកសាងភាពជាដៃគូ ដូច្នេះសម្តេចសូមប្រកាសស្វាគមន៍ការអនុវត្តយន្តការសហការចែករំលែកព័ត៌មានដើម្បីរួមគ្នាដោះស្រាយបញ្ហា។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ កម្ពុជាមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានមក តម្កល់សំណុំឯកសារ និងចុះបញ្ជីសរុបចំនួន៥.៥៦៤ ក្នុងនោះ សមាគមជាង ២.២០០ និងអង្គការជាង ៣.១០០អង្គការ៕



*លោក ប៊ុន ហ៊ុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ រូបភាព៖ ក្រសួងមហាផ្ទៃ*

*លោក ហ្វា សាលី ប្រធានសម្ព័ន្ធសហជីពជាតិកម្ពុជា។ រូបភាព៖ ហ្វេសប៊ុក*

# ការីតាសកម្ពុជា លើកកម្ពស់ការអប់រំ សម្រាប់ជនជាតិដើមភាគតិច

*ដោយ៖ លី សុវណ្ណា*



*ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងថ្នាក់ដឹកនាំអង្គការការីតាស លោកអភិបាលអូលីវីយេ លោកអភិបាល អេនរីគេ លោក គឹម រតនា ជានាយកប្រតិបត្តិ ថតរូបអនុស្សាវរីយជាមួយអ្នកចូលរួមកម្មវិធី។* រូបភាព៖ លី សុវណ្ណា

អគារថ្មីមួយខ្នង សម្ភារ បរិក្ខា ប្រព័ន្ធទឹកស្អាត បង្គន់អនាម័យ និងសមិទ្ធផលផ្សេងៗទៀត នៅសាលាបឋមសិក្សាស្រែអ៊ីដែលជាការអំណោយនៃគំរោងរួមគ្នារវាងក្រសួងបរិស្ថាន និងអង្គការការីតាស កម្ពុជា(Caritas) ត្រូវបានកាត់ខ្សែបូរសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២ ខែមករា ឆ្នាំ២០២០ កន្លងទៅ ដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តមសាយ សំអាល់ និងថ្នាក់ដឹកនាំអង្គការការីតាសកម្ពុជា មានលោកអភិបាល អេនរីគេ ហ្វីកាវេដូ លោកអភិបាលអូលីវីយេ ឆ្មិតអីស្ល៊េរ និងលោក គឹម រតនា ជានាយកប្រតិបត្តិ។

សហគមន៍ស្រែអ៊ីមានចំងាយប្រមាណជា ២០ គីឡូម៉ែត្រ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជាសហគមន៍ជនជាតិដើមភាគតិចពូណាង (ព្នង)។

លោក គឹម រតនា បានឲ្យដឹងថា ការផ្ដើមកសាងអគារថ្មីនៅសាលាបឋមសិក្សាស្រែអ៊ីគឺដើម្បីផ្ដល់សេវាអប់រំតាមកម្មវិធីរបស់រដ្ឋ និងជាភាសាខ្មែរដល់កូនៗរបស់ប្រជាសហគមន៍ស្រែអ៊ីដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិកែវសីម៉ា ក្នុងគោលដៅលើកកម្ពស់សមត្ថភាពប្រជាសហគមន៍ដែលជាជនជាតិដើមភាគតិច ដើម្បីទទួលបាននូវឱកាសធ្វើសមាហរណកម្ម និងអាចចូលរួមយ៉ាងសកម្មទៅក្នុងសកម្មភាពសេដ្ឋកិច្ចជាតិដែលកំពុងរីកចម្រើន ព្រមទាំងអាចទទួលបានផ្លែផ្កាពីការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ជាតិយើង ជាពិសេសឈប់ពឹងផ្អែកទៅលើផលនិងអនុផលព្រៃឈើនាពេលអនាគត។

លោកបន្តថា សាលាបឋមសិក្សាស្រែអ៊ីចាប់ផ្ដើមសាងសង់តាំងពី ខែកក្កដា ឆ្នាំ២០១៦ និងបញ្ចប់ជាស្ថាពរនៅ ឆ្នាំ២០១៨ ដោយចំណាយថវិកាសរុបចំនួន ៩ម៉ឺនដុល្លារ ក្រោមកិច្ចសហការឧបត្ថម្ភពីក្រសួងបរិស្ថាន និងគម្រោងផ្អែកប្រែប្រួលអាកាសធាតុនៃកម្មវិធីអភិវឌ្ឍរបស់រដ្ឋាភិបាលអាល្លឺម៉ង់ BMZ តាមរយៈអង្គការការីតាសកម្ពុជា។ ការសាងសង់សាលាបឋមសិក្សាស្រែអ៊ីនេះគឺជាគំនិតផ្ដួចផ្ដើមដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

គម្រោងនេះមិនត្រឹមតែសាងសង់សាលារៀនថ្មីប៉ុណ្ណោះទេ ប៉ុន្តែជាការបង្កើតឲ្យមាននូវ អគារធនធានវប្បធម៌ដើម្បីថែរក្សាវប្បធម៌ប្រពៃណីជនជាតិដើម ភាគតិចនៅក្នុងសហគមន៍ ចែករំលែកបទពិសោធន៍ សម្រាប់កូនចៅ ជំនាន់ក្រោយ។ តាមលោក គឹម រតនា សាលានេះក៏បានបំពាក់នូវសម្ភារនានា ដើម្បីលើកកម្ពស់ដល់ការសិក្សាពីបំណិនជីវិត លើកកម្ពស់ទឹកស្អាត និងអនាម័យ បរិស្ថានសាលាបៃតង និងការអប់រំផ្សព្វផ្សាយអំពីទស្សនាទាន នៃការប្រែប្រួលអាកាសធាតុ និងការអភិរក្សធនធានធម្មជាតិផងដែរ។

ក្នុងរបាយការបញ្ជាក់ថា ការសាងសង់នោះរួមមាន៖ អគារសាលារៀនចំនួន ១ខ្នងមាន៥បន្ទប់ ទំហំបណ្ដោយ៤០ម៉ែត្រ និងទទឹង ៩ម៉ែត្រ (ធ្វើពីឈើប្រក់ក្បឿង)។ តុសិស្ស និងតុសម្រាប់គ្រូ ចំនួន ១៣៥ ធ្វើពីឈើ។ បង្គន់អនាម័យ ១ខ្នងចំនួន ៤បន្ទប់ បែងចែកជាបន្ទប់ទឹកប្រុស ស្រី ដោយមានភ្ជាប់នូវរ៉េមសម្រាប់ជនមានពិការភាព។អណ្ដូងទឹកបូមដោយប្រព័ន្ធសូឡាចំនួន១ និងអាងស្តុកទឹកចំនួន១ សម្រាប់ប្រើប្រាស់នៅក្នុងសាលា និងសហគមន៍នៅជុំវិញសាលា។ អគារធនធានមនុស្ស និងបណ្ណាល័យ ចំនួន១ខ្នង ទំហំ៩ម៉ែត្រx៩,២ម៉ែត្រ សម្រាប់ដាក់សម្ភារវប្បធម៌ជនជាតិដើមភាគតិច ឯកសារ និងជាបន្ទប់ប្រជុំផ្សព្វផ្សាយ ទីចាត់ការមាន ទំហំ ៨,៥ម៉ែត្រx៩,២ម៉ែត្រ។ រៀបចំទីធ្លាសាលារៀន សួនច្បារ និងសួនដំណាំក្នុងទីធ្លាសាលារៀន ក្លោងទ្វារសាលា នឹងដងទង់ជាតិជាដើម។ ឧបករណ៍ចំរោះទឹកស្អាតសំរាប់ផឹក និងកន្លែងលាងដៃសិស្ស។

ក្នុងនោះអង្គការការីតាស ក៏មានគម្រោងអភិឌ្ឍទេសចរណ៍ធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិស្រែអ៊ីគឺជាគម្រោងអភិវឌ្ឍបន្ថែមដើម្បីផ្សាភ្ជាប់នឹងអគារធនធានវប្បធម៌ដែលបានសាងសង់រួចមក និងដោយផ្អែកលើសក្ដានុពលនៃធនធានធម្មជាតិនៅក្នុងសហគមន៍ ក៏ដូចជាធនធានមនុស្សគឺសហគមន៍អេកូទេសចរណ៍ស្រែអ៊ីដែលមានស្រាប់។

ក្នុងពិធីដ៏សេសសិសាលនេះ លោករដ្ឋមន្ត្រីក្រសួងបរិស្ថាន សាយ សំអាល់ បានកោតសសើរ ចំពោះកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការល្អរបស់អង្គការការីតាសកម្ពុជា ជាមួយក្រសួងបរិស្ថាន ក៏ដូចជាបានចូលរួមកសាងធនធានមនុស្ស អភិវឌ្ឍសហគមន៍ និងផ្ដល់សេវាផ្សេងៗទៀត ដើម្បីកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបាននាំមកនូវសន្តិភាពពេញលេញសម្រាប់ប្រជាជនកម្ពុជា។

អង្គការ ការីតាសកម្ពុជាបានបង្កើតឡើងក្នុងទសវត្ស ៧០ ក្នុងពេលប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាម ដែលមានពលរដ្ឋជាច្រើនភៀសសឹកចូលក្នុងក្រុងភ្នំពេញ ដើម្បីជួយសម្រួលដល់ប្រជាជនឲ្យគេមានម្ហូបអាហារ។ នេះបើតាមលោកអភិបាលអូលីវីយេ។

លោកបន្តថា ក្នុងឆ្នាំ១៩៧៥ សកម្មភាពមនុស្សធម៌ទាំងឡាយត្រូវឈប់ទាំងស្រុង។ លោកថា ក្នុងឆ្នាំ ១៩៩០ អង្គការនេះត្រូវបានបង្កើតឡើងសារជាថ្មី ក្រោមអនុស្សារណៈយោគយល់ជាមួយរាជរដ្ឋាភិបាល ដោយមានសកម្មភាព ស្តារនិងអភិវឌ្ឍ ព្រមទាំងសុខមាលភាព ជាពិសេសអ្នកក្រីក្រ កុមារកំព្រា និងជនងាយរងគ្រោះ។ អង្គការ ការីតាសកម្ពុជា ជាដៃស្តាំរបស់ព្រះសហគមន៍កាតូលិក កំពុងអនុវត្តសកម្មភាព និងអភិវឌ្ឍចំរុះនៅក្នុងគោលដៅសរុប ១៥រាជធានីខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងរយៈពេល៣០ឆ្នាំនៃការបំពេញបេសកកម្មមានផលផ្លែជាច្រើន សម្រាប់សង្គមកម្ពុជា ជាមួយគ្នានេះ ក៏មាននូវឧបស័គ្គ មួយចំនួនផងដែរ។ លោកអភិបាលគឺគេប្រធានប្រឹក្សាភិបាលអង្គការនេះបានប្រាប់ថា ដោយសារសង្គ្រាម បងប្អូនរង់ចាំឲ្យអង្គការជួយតែគេមិនបានជួយខ្លួនគេ។ ឧបសគ្គនេះដើម្បីឲ្យយើងរៀន នឹងរកមធ្យោបាយថ្មី។ លោកបន្តថា មួយទៀត គឺកត្តាសេដ្ឋកិច្ចយើងពឹងផ្អែកច្រើនលើធនធានពីខាងក្រៅ។ ហេតុនេះការីតាសបានខិតខំរកវិធីដើម្បីឲ្យបងប្អូនមានលំនឹងខាងសេដ្ឋកិច្ច ទុកចិត្តខ្លួនឯង ដើម្បីរីកចំរើន និងបន្តដំណើរការទៅខាងមុខ។

សម្រាប់ខេត្តមណ្ឌលគិរី អង្គការនេះមានវត្តមានក្នុងឆ្នាំ២០០៧ តបតាមការអញ្ជើញរបស់លោក អន់តូនី សាមី ស៊ូសែរាជ្យ ដែលជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។ ការីតាសខេត្តមណ្ឌលគិរីបានធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន បាននិងកំពុងអនុវត្តនូវគម្រោងអភិវឌ្ឍសហគមន៍ចំរុះ គម្រោងសុខភាពសហគមន៍ និងទឹកស្អាត ដែលមានគោលដៅក្នុងស្រុកពេជ្រាដា ក្នុងឃុំចំនួន៣ គឺឃុំប៊ូស្រា ក្រាំងតេះ ពូជី និង ស្រែអំពូម។ នៅក្នុងឆ្នាំ២០១២ បន្ថែមនូវគម្រោងមួយទៀតគឺ សុខភាពទឹកស្អាត និងអប់រំវិជ្ជាជីវៈក្នុងពន្ធនាគារ៕





*ឯកឧត្តម សាយ សំអាល់ កាត់ខ្សែបូរសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធិផលនានានៅសាលាបឋមសិក្សាស្រែអ៊ី។* រូបភាព៖ លី សុវណ្ណា





# ពលរដ្ឋត្រូវតែដឹងថាក្នុងមួយថ្ងៃគ្រោះថ្នាក់ចរាចរណ៍ សម្លាប់មនុស្សប្រមាណជា ៥,៨ នាក់

*ដោយ៖ អរិយបុត្រ*



*(រូបតូច) គ្រោះថ្នាក់ចរាចរណ៍ដែលបានកើតឡើងកន្លងមក។* រូបភាព៖ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ពលរដ្ឋកម្ពុជាហាក់ដូចជារំភើយ ហើយមិនសូវយកចិត្តទុកដាក់នៅឡើយទេរឿងគ្រោះថ្នាក់ចរាចរណ៍ ខណៈដែលមានរបាយការណ៍ចេញមកថា វាគឺជាគ្រោះថ្នាក់ដ៏គួរឲ្យរន្ធត់ និងក្លាយជាឃាតករលាក់មុខសម្លាប់ពលរដ្ឋយើងនៅក្នុងមួយថ្ងៃគិតជាមធ្យមលើសពី៥ នាក់។

លោក រុន ភក្ដី ដែលជាអ្នកបើកបរឡាំប្រឺតា ដែលយើងតែងហៅថា តុកតុកឥណ្ឌាមួយរូប បានឲ្យដឹងថា លោកតែងតែឮអំពីគ្រោះថ្នាក់ចរាចរណ៍នេះ ហើយក៏ធ្លាប់ជួបខ្លួនឯង ជាបន្តបន្ទាប់ដែរ នៅពេលដែលបើកបរ ប៉ុន្តែមិនដឹងជាធ្វើម៉េច។

លោកបានបញ្ជាក់ថា៖ «មិនដឹងជាធ្វើយ៉ាងម៉េចទេឥឡូវនេះ ពេលខ្លះចង់គោរពច្បាប់ចរាចរណ៍ដែរ តែបើយើងគោរពពេក វាមិនទៅមុខរួច ចឹងគេម៉េចយើងម៉េចដែរទៅ»។

លោកភក្ដីបានបន្តថា បើកបរនៅលើផ្លូវសព្វថ្ងៃនេះ ពិតជាគ្រោះថ្នាក់មែនជាពិសេសគឺនៅពេលយប់ហើយ លោកក៏ធ្លាប់ជួបគ្រោះថ្នាក់ផងដែរ ដូច្នេះហើយបានជាលោកឈប់រត់នៅពេលយប់ហើយ មករត់តែពេលពីពេលព្រលឹមរហូតដល់ព្រលប់ តែប៉ុណ្ណោះ។

អ្នកបើកឡាំប្រឺតាមួយរូបទៀតដែលអះអាងថាឈ្មោះ រឿង ចាន់រស្មី បានឲ្យដឹងថា លោកធ្លាប់ទៅរៀនច្បាប់ចរាចរណ៍នឹងគេដែរ ហើយក៏ដឹងឆ្វេងដឹងស្តាំ ដែរ ប៉ុន្តែលោកបាននិយាយដោយត្រង់ៗថា បើគោរពតាមច្បាប់នេះពេកគឺមិនបាច់រកស៊ីទាន់គេទេ។

លោកបានបញ្ជាក់ថា៖ «ឥឡូវនេះបើគោរពតែយើង ដោយបើកបរតាមគន្លង ហាមជែងហាមអីនោះ គឺដឹងថា ទៅមិនរួចហ្នឹង ម៉ូយគេវាត់ចោលអស់ ពីព្រោះតែមិនសូវមានអ្នកគោរពច្បាប់»។

លោកបានបន្តទៀតថា ដោយសារតែស្ថានភាពវាដូច្នេះ គឺមិនដឹងជាធ្វើយ៉ាងណានោះទេ គឺគេម៉េច គឺយើងចឹងទៅ។

លោក ដេត បញ្ញាឫទ្ធិ ជាប្រជាពលរដ្ឋវ័យ ៤២ ឆ្នាំ បានឲ្យដឹងថា នៅពេលដែលបើកបរ គឺនៅស្រុកយើងភាគច្រើនឆ្លៀតឱកាសទៅវិញទៅមក ។នៅលើទ្រូងផ្លូវ ជាពិសេស គឺនៅតាមទីក្រុង និយាយឲ្យចំនៅរាជធានី គឺគ្មានគម្លាតគ្មានអីច្បាស់លាស់នោះទេ ។ហើយនៅតាមភ្លើងស្តុបវិញនោះ ក៏គ្មានអ្នកណាប្រកាន់គំនូសច្បាស់លាស់ទេ គឺដឹងតែដណ្ដើមគ្នាទៅមុខជានិច្ច។

លោកបានបន្តទៀតថា ទាំងនេះគឺដោយសារតែយើងគ្មានសីលធម៌ និង ចូលចិត្តបំពានលើច្បាប់ ដូច្នេះ ហើយបានជាស្ថានភាពវាទៅជាពិបាកគ្រប់គ្រង។

ទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍វិញ លោកបានរំពឹងថា ពិតជាមិនអាចមានការថមថយចុះនោះទេ ដរាបណាច្បាប់ចរាចរណ៍មិនត្រូវបានអនុវត្តពេញលេញ ហើយយើងទាំងអស់គ្នា នៅមានបញ្ហាសីលធម៌នៅក្នុងការបើកបរ។

ទាក់ទិននឹងគ្រោះថ្នាក់ចរាចរណ៍នេះ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានឲ្យដឹងថា គិតជាមធ្យមក្នុងមួយថ្ងៃមានមនុស្សស្លាប់ ៥,៨នាក់ ដោយសារតែគ្រោះថ្នាក់ចរាចរណ៍។

ប្រភពដដែលបានបន្តថា ពេញមួយឆ្នាំ២០១៩ គ្រោះថ្នាក់ចរាចរណ៍នៅទូទាំងប្រទេសបានកើតចំនួន ៤,១២១លើក សម្លាប់មនុស្ស ១,៩៨១នាក់ និងរងរបួស ៦,១៩១នាក់។

ជុំវិញបញ្ហាគ្រោះថ្នាក់ចរាចរណ៍នេះ ថ្នាក់ដឹកនាំប្រទេស ជាពិសេសគឺក្រសួងមហាផ្ទៃ ក៏បានដឹងយ៉ាងច្បាស់អំពីបញ្ហានេះ។

សម្ដេច ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយក៏ជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានថ្លែងក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២០ ថ្មីៗនេះថា គ្រោះថ្នាក់ចរាចរណ៍គឺពិតជាស្រួចស្រាវមែន។

សម្ដេចបានឲ្យដឹងថា ស្ថានភាពចរាចរណ៍គឺជាបញ្ហាដ៏គួរឲ្យព្រួយបារម្ភ ដោយសារតែពេលនេះមធ្យោបាយធ្វើដំណើរមានកំណើនចំនួន ៣៧% ដែលបច្ចុប្បន្នទូទាំងប្រទេសមានយានយន្តសរុប ៥.៣៣៨.៣៩៤គ្រឿង ក្នុងនោះម៉ូតូមានចំនួន ៤.៥៥៥. ២២១គ្រឿង ស្មើ នឹង ៨៣% និងរថយន្តគ្រប់ប្រភេទមានចំនួន ៧៨៣.១៧៣ គ្រឿង ស្មើនឹង ១៧% ដោយបានធ្វើឱ្យសកម្មភាពចរាចរណ៍នៅទូទាំងប្រទេសកាន់តែមានភាពមមាញឹក និងកាន់តែចង្អៀត។

សម្ដេចបាន បន្តថា ស្ថានភាពបែបនេះ បានបង្កើតឲ្យមានបញ្ហាប្រឈមមួយចំនួនដូចជា ការកកស្ទះនៅតាមដងផ្លូវ តាមទីក្រុង ទីប្រជុំជន និងគ្រោះថ្នាក់ចរាចរណ៍មានការកើនឡើង ស្របពេលដែលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់មិនទាន់ឆ្លើយតបតាមតម្រូវការ ក៏ដូចជាកង្វះចំណតយានយន្ត កង្វះការគ្រប់គ្រងចំណីផ្លូវ និងកង្វះការបំពាក់បរិក្ខាសុវត្ថិភាពផ្លូវជាដើម។

សម្ដេចបានឲ្យដឹងថា ផ្អែកតាមមតិយោបល់ដែលបានចូលរួមលើកឡើងក្នុងអង្គពិធី និងផ្អែកតាមការសិក្សាស្រាវជ្រាវរបស់អង្គភាពជំនាញ យើងបានរកឃើញមូលហេតុ និងបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលជាកត្តាធ្វើឲ្យមានកំណើនគ្រោះថ្នាក់ចរាចរណ៍ និងធ្វើឲ្យការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកពុំទាន់មានប្រសិទ្ធភាពខ្ពស់។ បញ្ហាទាំងនោះវារួមផ្សំជាមួយនឹងបញ្ហានៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ថ្មីបើបាន និងកំពុងបន្តជួសជុល និងកសាងប៉ុន្តែមិនទាន់ឆ្លើយតបតាមល្បឿននៃកំណើនយានយន្ត ដែលត្រូវធ្វើសកម្មភាពចរាចរណ៍ និងដឹកជញ្ជូន។ ទន្ទឹមនេះផងដែរ កង្វះការគ្រប់គ្រងទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ការបំពាក់បរិក្ខាសុវត្ថិភាពនៅតាមដងផ្លូវមួយចំនួនមិនទាន់គ្រប់គ្រាន់ដូចជា ស្លាកសញ្ញា គំនូសសញ្ញា ភ្លើងសញ្ញា ភ្លើងបំភ្លឺជាដើម ដែលជាហេតុនាំឱ្យចរាចរណ៍ងាយប្រឈមនឹងការកកស្ទះ និងមានគ្រោះថ្នាក់។

សម្ដេចបានបន្តទៀតថា ស្មារតីគោរពច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតនៅតែខ្លាចនគរបាលជាជាងខ្លាចច្បាប់ ព្រមទាំងបានបង្កគ្រោះថ្នាក់តាមរយៈការបើកបរលើសល្បឿនកំណត់ មិនគោរពសិទ្ធិអាទិភាព មិនគោរពសញ្ញាចរាចរណ៍ មិនពាក់មួក ឬខ្សែក្រវាត់សុវត្ថិភាព មិនប្រកាន់ស្តាំ វ៉ាជែងប្រថុយប្រថាន បត់មិនប្រុងប្រយ័ត្ន ស្រវឹង និងបើកបរទាំងងងុយ ។ល។

ផ្អែកតាមការវិភាគ គ្រោះថ្នាក់នៅពេលយប់មានចំនួន ៥៥% ដោយអ្នកស្លាប់ភាគច្រើន ជាអ្នកជិះម៉ូតូមានចំនួន ៧៨% ក្នុងនោះមិនពាក់មួកសុវត្ថិភាពចំនួន៧៧%៕



*ការបើកបរទោចក្រយានយន្តប្រកបដោយគ្រោះថ្នាក់។* រូបភាព៖ ស៊ីអេស៊ី

# អ្នកសារព័ត៌មានបច្ចុប្បន្នមានក្រុមមេធាវីសម្រាប់ជួយការពារក្តី


*លោកមេធាវី គី តិច ប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ។*
*រូបភាព៖ មេធាវីស្ម័គ្រចិត្តសម្តេចតេជោ*

*ដោយ៖ អរិយបុត្រ*

រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍ថា អ្នកសារព័ត៌មានកម្ពុជានៅពេលបច្ចុប្បន្ននេះ មានក្រុមមេធាវីសម្រាប់ជួយការពារក្តីហើយ នៅក្នុងករណីមានក្តីក្តាំងនៅក្នុងកិច្ចការវិជ្ជាជីវៈនោះ។

បើតាមលោករដ្ឋមន្ត្រីក្រសួងព័ត៌មាន ក្រុមមេធាវីដែលនឹងជួយការពារក្តីដល់ក្រុមអ្នកសារព័ត៌មាននោះ គឺជាក្រុមមេធាវីរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។

គួររំលឹកថា កាលពីខែ មករា ដើមឆ្នាំកន្លងទៅនេះ ក្រសួងព័ត៌មានបានស្នើសុំឲ្យមានមេធាវីសម្រាប់ជាមួយនឹងលោក គី តិច ប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេច តេជោ ហ៊ុន សែន កាលពីថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២០។

នៅក្រោយពេលកិច្ចប្រជុំនោះ លោក រដ្ឋមន្ត្រីបានថ្លែងបញ្ជាក់ថា ក្រសួងព័ត៌មាន និងក្រុមមេធាវីនោះ គឺបានកំណត់គោលដៅនៅក្នុងការជួយក្រុមអ្នកសារព័ត៌មានដែលមានបញ្ហាផ្លូវច្បាប់។

លោក ខៀវ កាញារីទ្ធ បានកំណត់ថា ក្រសួងព័ត៌មាន និង ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ នឹងជួយគាំទ្រផ្លូវច្បាប់ ជួយតែអ្នកកាសែតដែលមានវិជ្ជាជីវៈតែប៉ុណ្ណោះ ហើយ អ្នកដែលមិនមានវិជ្ជាជីវៈ មិនជួយទេ។

> មុនពេលក្រុមមេធាវីសម្រេចផ្តល់សេវាមេធាវីគឺត្រូវឆ្លងកាត់ក្រសួងព័ត៌មានជាមុនសិន។ សេវាមេធាវីនឹងត្រូវផ្តល់ជូនទៅដល់ចំពោះតែអ្នកសារព័ត៌មានដែលបានប្រកបវិជ្ជាជីវៈត្រឹមត្រូវ តែក្នុងករណីអ្នកសារព័ត៌មានប្រកបវិជ្ជាជីវៈមិនត្រឹមត្រូវទេ មិនផ្តល់មេធាវីជូនទេ។



*ប្រធាន និងសមាជិកក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ ប្រជុំលើកដំបូង។ រូបភាព៖ ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ*

ការពារក្តី នៅក្នុងករណីដែលមានវិវាទនៅលើផ្លូវតុលាការដោយសារតែបញ្ហាវិជ្ជាជីវៈសារព័ត៌មាន ទៅដល់ប្រមុខរាជរដ្ឋាភិបាលកម្ពុជានៅក្នុងអំឡុងពេលរៀបចំជំនួបរវាងប្រមុខរាជរដ្ឋាភិបាល និងអ្នកសារព័ត៌មាននានា។

ក្រោយពេលដែលសម្តេចតេជោ ហ៊ុន សែន បានផ្តល់ភ្លើងខៀវ លោក ខៀវ កាញារីទ្ធ នៅក្នុងនាមក្រសួងព័ត៌មានបានរៀបចំនូវកិច្ចប្រជុំមួយ

លោករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា លោកខ្លាចបំផុតអ្នកកាសែតគ្មានវិជ្ជាជីវៈ មុនពេលមានការជួយអន្តរាគមន៍ពីមេធាវីស្ម័គ្រចិត្ត គឺត្រូវឆ្លងក្រសួងព័ត៌មានសិន។

ជុំវិញបញ្ហានេះ លោក គី តិច បានថ្លែងថា អ្នកកាសែតដែលប្រកបដោយវិជ្ជាជីវៈ គឺងាយស្រួលការពារហើយបានសម្តែងការឯកភាពជាមួយលោករដ្ឋមន្ត្រីដែលថា មុនពេលក្រុមមេធាវីសម្រេចផ្តល់សេវាមេធាវីគឺត្រូវឆ្លងកាត់ក្រសួងព័ត៌មានជាមុនសិន។

លោកបានបន្តថា អនុវត្តតាមអនុសាសន៍សម្តេចតេជោ ហ៊ុន សែន ដែលសម្តេចបានមានប្រសាសន៍នៅក្នុងពិធីជួបជុំជាមួយអ្នកសារព័ត៌មានកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ សេវាមេធាវីនឹងត្រូវផ្តល់ជូនទៅដល់ចំពោះតែអ្នកសារព័ត៌មានដែលបានប្រកបវិជ្ជាជីវៈត្រឹមត្រូវ តែក្នុងករណីអ្នកសារព័ត៌មានប្រកបវិជ្ជាជីវៈមិនត្រឹមត្រូវទេ មិនផ្តល់មេធាវីជូនទេ។

លោកបានបន្តថា ក្រសួងព័ត៌មាននឹងរៀបចំសិក្ខាសាលាមួយដើម្បីបញ្ជ្រៀបការយល់ដឹងពាក់ព័ន្ធទៅនិងបញ្ហាផ្តល់សេវាមេធាវីជួយការពារអ្នកសារព័ត៌មានដែលមានវិជ្ជាជីវៈត្រឹមត្រូវ។

ឆ្លើយតបនឹងបញ្ហានេះ អ្នកសារព័ត៌មានភាគច្រើនបានសំដែងនូវការគាំទ្រចំពោះគំនិតផ្តួចផ្តើមនេះ ប៉ុន្តែ អ្នកសារព័ត៌មានមួយចំនួនក៏បានដាក់ការសង្ស័យផងដែរទៅលើអព្យាក្រិតភាពនៃក្រុមមេធាវីនេះ ដោយសារតែមេធាវីទាំងអស់សុទ្ធសឹងជាក្រុមមេធាវីដែលស្និតនឹងរាជរដ្ឋាភិបាល។

អ្នកសារព័ត៌មានដែលសុំមិនបញ្ចេញអត្តសញ្ញាណមួយរូបបានថ្លែងថា យើងមានមេធាវីគឺជារឿងដែលគួរឲ្យអបអរហើយ ប៉ុន្តែនៅក្នុងករណីយើងមានក្តីក្តាំងជាមួយនឹងមន្ត្រីរាជរដ្ឋាភិបាលវិញ តើយើងអាចជឿទុកចិត្តទៅលើអព្យាក្រិតភាពរបស់ពួកគាត់បានប៉ុណ្ណា។

គួររំលឹកថា រហូតមកដល់ពេលនេះប្រទេសកម្ពុជាមានអ្នកសារព័ត៌មានប្រហែលជាលើសពី ៦០០០ នាក់។ ពួកគេទាំងនោះ ខ្លះបានចូលរួមនៅក្នុងវិស័យនេះតែម្នាក់ឯងដោយឯករាជ្យតាមបណ្តាញសង្គម និង ខ្លះទៀត បម្រើការនៅតាមអង្គភាពប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពចំនួនប្រមាណជា ៣១០ អង្គភាព ៥០០ វិបសាយ និង ទូរទស្សន៍អនឡាញ ទូរទស្សន៍ជាង ២០ ស្ថាប័ន វិទ្យុជាង ២២០ សមាគមនចំនួន ៤២ និងតំណាងអង្គភាពសារព័ត៌មានបរទេសចំនួនជាង២០ស្ថាប័នថែមទៀត៕


*រូបភាព៖ ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ*


*ក្រុមមេធាវីជួយការពារក្តីជូនជនរងគ្រោះក្នុងករណីបាក់រលំអាគារនៅក្នុងខេត្តព្រះសីហនុនាពេលកន្លងមក។ រូបភាព៖ ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ*





# កិច្ចប្រជុំCACDរិះគិតលើប្រធានបទ៖ «ចូរ ធ្វើជាអ្នកកសាងសន្តិភាព»

*ដោយ៖ លី សុវណ្ណា*

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ នេះសម្ពន្ធអង្គការកាតូលិក ដើម្បីមេត្តាករុណា និងការអភិវឌ្ឍ ហៅកាត់ថា CACD បានជួបប្រជុំប្រចាំ ដែលមានអ្នកចូលរួមចំនួនប្រមាណជាង៤០នាក់។

CACD មានសមាជិកជាង២០ អង្គការ សមាគម ព្រមទាំងការិល័យ និងគណៈកម្មការព្រះសហគមន៍ភូមិភាគភ្នំពេញ។ ក្នុងកិច្ចប្រជុំនេះ CACD បានរិះគិតលើប្រធានបទ ៖ «ចូរ ធ្វើជាអ្នកកសាងសន្តិភាព»។

លោកអភិបាលអូលីវីយេ បានណែនាំអង្គប្រជុំ និងបានបំភ្លឺសមាជិកទាំងអស់អំពីដំណើរនៃសន្តិភាពតាមសារលិខិតរបស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ សម្រាប់ទិវា សន្តិភាពពិភពលោក២០២០។ ក្នុងពេលនោះលោកអភិបាលក៏បានជំរុញឲ្យសមាជិកទាំងអស់យកចិត្តទុកដាក់និងចង់ចាំអត្តសញ្ញាណរបស់ខ្លួនជាអង្គការតូលិក ទោះបីជាអង្គការអន្តរជាតិ អង្គការជាតិ ក្រុមបព្វជិតបព្វជិតា ព្រមទាំងព្រះសហគមន៍កាតូលិក និងការិយាល័យមួយចំនួនឲ្យដឹងថាយើងនៅទីនេះ គឺតំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជា និងព្រះសហគមន៍នានាក្នុងពិភពលោក ដែលមកបម្រើ និងប្រកាសអំពីព្រះរាជរបស់ព្រះជាម្ចាស់។

លោកថាព្រះរាជរបស់ព្រះជាម្ចាស់គឺជំបូងបង្អស់ ណែនាំឲ្យមនុស្សទាំងអស់មានសុភមង្គល និងពេញដោយសេចក្តីសុខសាន្ត។

លោកបានបន្តលើកឡើងទៀតថា ចូរនឹកឃើញជាក់ស្តែងពីតួនាទីបេសកកម្មរបស់យើងខុសៗគ្នា តែយើងមានប្រភពតែមួយ គឺប្រកាសអំពីព្រះរាជរបស់ព្រះជាម្ចាស់ និងនាំមនុស្សឲ្យទទួលសេចក្តីសុខរួមជាមួយព្រះអង្គ។

ក្នុងនោះដែរ ក៏មានបទបង្ហាញពីអ្នកជំនាញ ដែលមានបទពិសោធន៍ក្នុងការកសាងសន្តិភាពផងដែរ។

CACD ចាប់តាំងពីឆ្នាំ២០១១ មកតែងជួបជុំគ្នា រៀងរាល់បីខែម្តង ដោយមានចែករំលែកបទពិសោធន៍ និងព័ត៌មានផ្សេងៗរួមជាមួយគ្នា ព្រមទាំងបានលើកផែនការអនុវត្តរួមគ្នាផងដែរ ដើម្បីជាប្រយោជន៍រួមសម្រាប់កម្ពុជា៕


*អ្នកជំនាញធ្វើបទបង្ហាញដល់សមាជិកកិច្ចប្រជុំរបស់ CACD។ រូបភាព៖ ស៊ីអេសស៊ី*



*លោកអភិបាលអូលីវីយេ នៅក្នុងកិច្ចប្រជុំសម្ពន្ធអង្គការកាតូលិក ដើម្បីមេត្តាករុណា និងការអភិវឌ្ឍ*
*រូបភាព៖ ស៊ីអេសស៊ី*



*សមាជិកជាង២០ អង្គការ សមាគម ព្រមទាំងការិល័យ និងគណៈកម្មការព្រះសហគមន៍ភូមិភាគភ្នំពេញចូលរួមក្នុងកិច្ចប្រជុំ។ រូបភាព៖ ស៊ីអេសស៊ី*



## ប្រាសាទអង្គរ ពេលព្រឹកព្រលឹម

ភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិ កំពុងរីករាយទស្សនា និងថតផ្តិតយករូបភាពថ្ងៃរះនាមុខប្រាសាទអង្គរវត្ត នាពេលព្រឹកព្រលឹម។

*រូបភាព៖ ស៊ីអេសស៊ី*

# បុណ្យភូមិជាពេលអរព្រះគុណព្រះជាម្ចាស់

*ដោយ៖ កែវ កញ្ញា*

ម៉ោងប្រមាណជា២រសៀល គោយន្តចំនួន៨គ្រឿងបានរៀបចំជាស្រេចដើម្បីធ្វើដំណើរទៅកាន់ផ្ទះនីមួយៗ ដោយនៅលើនោះមានដាក់ធុងទឹកមួយចំនួនផង។ លោកបូជាចារ្យកាតូលិកបានឡើងជិះគោយន្តនោះដោយបរយឺតៗពីផ្ទះមួយទៅផ្ទះមួយ រួមទាំងស្រោយទឹកជូនពរដល់ក្រុមគ្រួសារទាំងនោះ។

នៅតាមផ្លូវយើងឃើញមានគ្រួសារជាច្រើនទាំងគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទកំពុងឈររង់ចាំដំណើររបស់អស់លោក ហើយនៅខាងមុខផ្ទះរបស់ពួកគាត់ក៏មានដាក់ធុងទឹកមួយឬពីរថែមដោយផ្កាភ្ញីក្នុងនោះផង។

អង្គុយនៅលើកៅអីដោយសារលោកជាជនពិការជើងមួយចំហៀង នៅរង់ចាំទទួលទឹកពីលោកបូជាចារ្យដែលបានធ្វើដំណើរទៅដល់ផ្ទះ លោកឆាយ ឈឿម ជាពុទ្ធបរិស័ទ និងជាប្រជាជនរស់នៅក្នុងភូមិនេះ បាននិយាយថា «កម្មវិធីឆាន់ភូមិនេះ សប្បាយៗគឺដោយសារបានទឹកព្រះពរ។ លោកពុកដែលបានមកចូលរួមធ្វើបុណ្យភូមិ មកចាក់ទឹកចាក់អីនេះ គឺសប្បាយណាស់។ សូមឲ្យបងប្អូនព្រះសហគមន៍សប្បាយ មានសុខភាពល្អ»។

លោកឈឿម បន្តថា កម្មវិធីបុណ្យនេះ បានធ្វើឡើងជាច្រើនឆ្នាំមកហើយ ប៉ុន្តែលោកមិនបានចាំថាកើតឡើងក្នុងពេលណាទេ។

ចំណែកអ្នកស្រីចេង សួន អាយុ ៦៨ឆ្នាំ ដែលបានរង់ចាំទទួលទឹកព្រះពរដែរនោះ បានឲ្យដឹងថា «មានអារម្មណ៍សប្បាយដែលបានធ្វើបុណ្យនេះ ព្រោះអីធ្វើរាល់ឆ្នាំ។ គិតទៅវាប្រមាណ ១៧ទៅ១៨ឆ្នាំហើយ ធ្វើបុណ្យនេះ... ព្រះជាម្ចាស់ជួយថែរក្សា មានសុខភាពល្អ អត់សូវមានជំងឺរោគាអីមកបៀតបៀន មិនសូវមានឈឺ។ មុននឹងអែងឈឺ ហើយឥឡូវធ្វើបុណ្យធ្វើទានទៅ ដូចជាមានសុខភាពល្អ»។

អ្នកស្រីបន្ថែមទៀតថា រាល់ថ្ងៃសៅរ៍គាត់បានទៅចូលរួមជាមួយក្រុមព្រះមាតាដែលជាក្រុមមួយរៀបចំដោយព្រះសហគមន៍កាតូលិកមានកម្មវិធីសូត្រធម៌ផ្សេងៗ។

ព្រះសហគមន៍បានរៀបចំធ្វើកម្មវិធីបុណ្យភូមិនេះកាលពីឆ្នាំ២០០៤ ដោយហៅថាបុណ្យភូមិ។ បុណ្យនេះ



*លោកបូជាចារ្យម៉ានុច ស្រោយទឹកព្រះពរដល់ចាស់ៗតាមផ្ទះរបស់ពួកគាត់។ រូបភាព៖ ស៊ីអេសស៊ី*



*លោកបូជាចារ្យរួមគ្នាធ្វើទឹកព្រះពរមុនពេលធ្វើដំណើរតាមភូមិ។ ស៊ីអេសស៊ី*



*ប្រជាជនទទួលទឹកព្រះពរតាមផ្ទះនីមួយៗ ដើម្បីទទួលអំណរសប្បាយ សម្រាប់ឆ្នាំថ្មី។ រូបភាព៖ ស៊ីអេសស៊ី*

បានចម្លងចេញពីបុណ្យមួយរបស់អ្នកភូមិរង្វៀនលិច ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដែលគេបានធ្វើជារៀងរាល់ឆ្នាំ ដោយហៅឈ្មោះថា បុណ្យឆាន់ភូមិ។ បុណ្យនេះត្រូវបានធ្វើឡើងក្រោយពេលប្រជាពលរដ្ឋប្រមូលផលរួច។ នេះបើតាមលោកថែង យ៉ាត ជាប្រធានគណៈកម្មការព្រះសហគមន៍នេះ។

ព្រះវិហារសន្តីតេរេសានៃ ព្រះកុមារយេស៊ូរបស់ព្រះសហគមន៍ចំណោមបានរៀបចំបុណ្យនេះកាលពីថ្ងៃទី៥ ខែកុម្ភៈ ក្រោមអធិបតីភាពរបស់លោកអេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង រួមនិងបូជាចារ្យជាច្រើនអង្គ ដោយមានគ្រីស្តបរិស័ទនិងពុទ្ធបរិស័ទ

> **សូមធ្វើអំពើល្អដល់អ្នកដទៃ ដើម្បីបង្ហាញថា យើងជាគ្រីស្តបរិស័ទ។ ជំនឿរបស់យើង គឺ អរគុណ អធិដ្ឋាន និងបង្ហាញជំនឿ**

ចូលរួមយ៉ាងច្រើនកុះករ។

លោកថែង យ៉ាត បានឲ្យដឹងថា បុណ្យភូមិនេះ គឺមានន័យថា៖ «សាមគ្គីគ្នា រវាងសាសនានិងសាសនា រវាងប្រជាជនក្នុងភូមិឲ្យចេះរួមគ្នា ដើម្បីធ្វើអំពើល្អមួយ ដោយផ្តល់សេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក មិនប្រកាន់ពូជសាសន៍ និងសាសនា»។

លោកបន្ថែមថា សម្រាប់ព្រះសហគមន៍ ការធ្វើបុណ្យភូមិនេះ ដើម្បីអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានឲ្យយើងមានអ្វីៗក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ទាំងភោគផល ទាំងអ្វីទាំងអស់ដែលយើងបានមកពេញមួយជីវិតរបស់យើងទាំងសប្បាយចិត្ត និងទុក្ខលំបាក ថ្វាយទៅព្រះជាម្ចាស់។

«ខ្លះបានស្រូវ ខ្លះអត់បាន គ្នាកើតទុក្ខ មានតែមកសុំព្រះអង្គ ថ្វាយទុក្ខលំបាករបស់យើងរួមជាមួយបុណ្យភូមិនេះ» លោកយ៉ាតបញ្ជាក់។

គណៈកម្មការរូបនេះបន្ថែមថា បុណ្យភូមិនេះ គឺធ្វើឡើងសម្រាប់ព្រះសហគមន៍ភូមិភាគបាត់ដំបងទាំងមូល ក៏ដូចជាព្រះសហគមន៍នៅកម្ពុជា និងពិភពលោកទាំងមូលដែរ។

លោកយ៉ាតបញ្ជាក់ថា កម្មវិធីនេះធ្វើឡើងរៀងរាល់មួយឆ្នាំម្តងនៅមុនរដូវច្រូតស្រូវ និងក្រោយពេលប្រមូលផលរួច។

មុននឹងចាប់ផ្តើមកម្មវិធីស្រោចប្រោះព្រំតាមផ្ទះ ព្រះសហគមន៍បានរៀបចំ ឲ្យមានពិធីអភិបូជាដើម្បីអរព្រះគុណព្រះជាម្ចាស់តាមជំនឿរបស់គ្រីស្តបរិស័ទ។

លោកបូជាចារ្យបាណែណាល់ តូតែត មានប្រសាសន៍នៅក្នុងធម្មទេសនាថា ជីវិតរបស់យើង ត្រូវក្លាយជាជីវិតអរគុណព្រះជាម្ចាស់គ្រប់ពេល។ ថ្ងៃនេះជានិមិត្តរូបនៃការអរគុណព្រះជាម្ចាស់ ចំពោះភោគផលដែលយើងមាននៅក្នុងជីវិត។

លោកបូជាចារ្យលើកទឹកចិត្តដល់គ្រីស្តបរិស័ទឲ្យមានក្តីសង្ឃឹមជានិច្ច និងត្រូវអរគុណព្រះជាម្ចាស់មិនគ្រាន់តែចំពោះភោគផលប៉ុណ្ណោះ គឺត្រូវអរព្រះគុណ ចំពោះក្រុមគ្រួសារ ការរកស៊ីជាដើម ដើម្បីបញ្ជាក់ថា ជីវិតរបស់យើង គឺពឹងលើព្រះជាម្ចាស់។

ក្នុងនោះដែរ លោកបូជាចារ្យមានប្រសាសន៍ទៀតថា៖ «កុំភ្លេចអធិដ្ឋានចូលព្រះវិហារ» ដោយមិនគិតអំពីការមិនពេញចិត្តចំពោះបូជាចារ្យ បងស្រី ឬគណៈកម្មការរបស់ព្រះសហគមន៍។

លោកបានសុំឲ្យគ្រីស្តបរស័ទចាស់ៗបង្ហាញជំនឿ ជាគ្រីស្តបរិស័ទ និងបង្រៀនកូនចៅឲ្យចេះអធិដ្ឋាន និងស្គាល់ព្រះសហគមន៍។ លោកបន្ថែមឲ្យដឹងដូច្នេះថា៖ «កុំសួរថា ហេតុអ្វីកូនចៅអត់ចូលព្រះសហគមន៍ ព្រោះនៅពេលយើងនិយាយអាក្រក់ និងស្អប់ព្រះសហគមន៍ នាំឲ្យវាមិនចង់ស្គាល់ព្រះសហគមន៍ទេ»។

លោកក៏បានរំលឹកជាចុងក្រោយទៀតថា៖ «សូមធ្វើអំពើល្អដល់អ្នកដទៃ ដើម្បីបង្ហាញថា យើងជាគ្រីស្តបរិស័ទ។ ជំនឿរបស់យើង គឺអរគុណ អធិដ្ឋាន និងបង្ហាញជំនឿ»៕





# យុវជនរៀនធ្វើជាអ្នកកសាងសន្តិភាពដោយជំនឿ និងសកម្មភាព

*ដោយ៖ ដាលីស*

យុវជនកាតូលិក ជាង២០០នាក់ មកពីព្រះសហគមន៍នានានៃភូមិភាគភ្នំពេញ ធ្វើបូជនីយកិច្ចដោយថ្មើរជើងចេញពីព្រះវិហារសន្តយ៉ូហានបាទីស្ត ស្រុកបាទី ទៅកាន់ព្រះវិហារសន្តីតេរេសានៃព្រះកុមារយេស៊ូ ព្រៃកប្បាស ខេត្តតាកែវ ក្រោមការណែនាំផ្លូវវិញ្ញាណដោយលោកអភិបាល អូលីវីយេ ឆ្មឹតអីស្លែរ និងរៀបចំដោយការិយាល័យយុវជនជំទង់និងកុមារនៃភូមិភាគភ្នំពេញ ថ្ងៃទី ៨ និងទី៩ ខែកុម្ភៈឆ្នាំ ២០២០។

មុនពេលចាប់ផ្តើមធ្វើដំណើរ លោកអភិបាលបានក្រើនរំឭកដល់យុវជនឲ្យយល់ថា កម្មវិធីនេះគឺជាឱកាសមួយ ឲ្យពួកគាត់រកឃើញផ្លូវនៃសុភមង្គល ដើម្បី «ធ្វើជាអ្នកកសាងសន្តិភាព» នៅក្នុងពិភពលោកនេះ ដែលការកសាងសន្តិភាពតាមផ្លូវសុភមង្គលរបស់ព្រះយេស៊ូ ដោយយកចិត្តទុកដាក់ និងឥរិយាបទនៃដួងចិត្ត ៣យ៉ាងគឺ ដាក់ចិត្តជាអ្នកក្រខ្សត់ មានចិត្តស្លូតបូត និងមានចិត្តបរិសុទ្ធ។ ដាក់ចិត្តជាអ្នកក្រខ្សត់ មានចិត្តស្លូតបូត និងមានចិត្តបរិសុទ្ធ។

លោកបានបញ្ជាក់ចំណុចនីមួយៗ ដោយលើកព្រះបន្ទូលរបស់ព្រះយេស៊ូ អំពីសុភមង្គលដ៏ពិតប្រាកដ និងឧទាហរណ៍មួយចំនួន ដែលបានកើតមានក្នុងសង្គម។

ក្រុមបូជនីយេសក៍នេះ បានចែកចេញជា១០ក្រុម ដោយដើរចេញ ពីព្រះសហគមន៍បាទី ទៅកាន់សាលាបឋមសិក្សាប៊ុនរ៉ានីហ៊ុនសែនស្លារម បន្តដំណើរដោយឆ្លងកាត់កំពូលភ្នំជីសូរ រហូតដល់ព្រះសហគមន៍ព្រៃកប្បាស ដែលមានរយៈចម្ងាយប្រមាណ២០គីឡូម៉ែត្រ។

នៅតាមកន្លែងឈប់សម្រាកនីមួយៗ លោកអភិបាលអូលីវីយេ បានធ្វើការអប់រំអំពីជំនឿដល់និងកិច្ចការងារដែលគ្រីស្តបរិស័ទត្រូវធ្វើនៅក្នុងសង្គម ដើម្បីប្រតិបត្តិជំនឿរបស់ខ្លួន។ ហើយការអប់រំ នេះ មានចែកចេញជាប្រធានបទផ្សេងៗ។

បន្ទាប់ពីបានបញ្ជាក់អំពីឥរិយាបទផ្លូវចិត្តទាំងបី ក្នុងការកសាងសន្តិភាព លោកអភិបាលក៏បានជំរុញ និងបំភ្លឺឲ្យយុវជនមានសកម្មភាពក្នុងជីវិតប្រចាំថ្ងៃ ដោយលើកយកវិន័យសំខាន់របស់ព្រះយេស៊ូ «ចូរស្រឡាញ់បងប្អូនឯទៀតៗ ដូចខ្ញុំស្រឡាញ់អ្នករាល់គ្នាដែរ» ជាការចាប់ផ្តើមក្នុងការអប់រំដំណាក់កាលទី២។ លោកអភិបាលបញ្ជាក់ថា ដើម្បីរស់នៅឲ្យមានសុភមង្គលយើងជាគ្រីស្តបរិស័ទត្រូវបញ្ចេញសកម្មភាព គឺ«ត្រូវមានចិត្តមេត្តាករុណា» ដោយយកចិត្តទុកដាក់ជាមួយឪពុកម្តាយ



*រូបភាពអនុស្សាវរីយ៍របស់យុវជននៅលើភ្នំជីសូរ ខេត្តតាកែវ។ រូបភាព៖ ស៊ីអេសស៊ី*





*យុវជនប្រជុំគ្នារិះគិតអំពី ប្រធានបទនៃបូជនីចរ។ រូបភាព៖ ស៊ីអេសស៊ី*

ក្រុមគ្រួសារ មិត្តភក្តិ និងអ្នកដទៃ។ មួយទៀតគឺ «ត្រូវស្រេកឃ្លានសេចក្តីសុច្ចរិត» គឺត្រូវធ្វើយ៉ាងម៉េចដើម្បីបង្កើតឲ្យមានយុត្តិធម៌នៅក្នុងសង្គម។ និងចុងក្រោយ «កសាងសន្តិភាព» ដើម្បីណែនាំមនុស្សទាំងអស់ឲ្យទៅជាមហាគ្រួសារតែមួយ ព្រោះថាក្នុងពិភពលោកត្រូវការជាងគេ គឺ «សន្តិភាព»។

លោកអភិបាលបានជំរុញ ឲ្យអ្នកចូលរួមត្រូវជួយអ្នកដទៃទៀត ឲ្យរកឃើញសេចក្តីសុខ ដោយអធិដ្ឋាន



*អធិដ្ឋានតាមបែបតេហ្សេ ដើម្បីរំលឹកនូវកិច្ចការទាំងឡាយដែលបានធ្វើ និងការរិះគិតអំពីជីវិតផ្ទាល់ខ្លួន និងជំនឿ។ រូបភាព៖ ស៊ីអេសស៊ី*



*លោកអភិបាល អូលីវីយេ ឆ្មឹតអីស្លែរ ដឹកនាំបូជនីយកិច្ចដោយថ្មើរជើង។ រូបភាព៖ ស៊ីអេសស៊ី*

ពឹងលើព្រះជាម្ចាស់ ហើយត្រូវអត់ទោសដល់គ្នាទៅវិញទៅមក។ «ការអត់ទោសនេះ ជាទ្រព្យសម្បត្តិដែលព្រះយេស៊ូប្រទានឲ្យយើងនៅលើឈើឆ្កាង ទ្រង់ក៏បានលើកលែងទោសឲ្យអ្នកដែលឆ្កាងព្រះអង្គដែរ» លោកអភិបាលបានបញ្ជាក់។

ធ្វើដំណើរពេញមួយថ្ងៃ ក្រុមនីមួយៗបានមកដល់ព្រះសហគមន៍ព្រៃកប្បាសដោយជោគជ័យ។ នៅល្ងាចថ្ងៃដដែលនោះ ក្រុមយុវជនបាននាំគ្នារៀបចំកម្មវិធីអធិដ្ឋានបែបតេហ្សេនៅពេលយប់ ដើម្បីរិះគិតឡើងវិញនូវការអប់រំក្នុងថ្ងៃនេះ និងត្រូវរកមធ្យោបាយផ្ទាល់ខ្លួនដើម្បីឲ្យទៅជាផលផ្លែសម្រាប់បេសកកម្មជាគ្រីស្តបរិស័ទ។

នៅព្រឹកថ្ងៃបន្ទាប់ក្រុមទាំងអស់បានចូលរួមអភិបូជា ដើម្បីបិទកម្មវិធី។

ក្នុងធម្មទេសនាលោកអភិបាលបានរំលឹកយុវជនទាំងអស់ថា ដើម្បីកសាងសន្តិភាពត្រូវចាប់ផ្តើមពីខ្លួនយើង ដោយដាក់ខ្លួនជាអ្នកក្រខ្សត់ ដាក់ចិត្តស្លូតបូត ជាអ្នកដែលមានសកកម្មភាពមេត្តាករុណា កសាងយុត្តិធម៌នៅក្នុងសង្គម។

លោកអភិបាលក៏បានលើកទឹកចិត្តអ្នកចូលរួមឲ្យយកចិតទុកដាក់ដាំ និងថែរក្សា អំណោយទានរបស់ព្រះជាម្ចាស់ គឺខិតខំរស់នៅដោយយល់ថា ខ្ញុំជាយុវជនជីវិតមានតម្លៃថ្លៃថ្នូរដោយមានព្រះបិតាតែមួយ។ យកចិត្តទុកដាក់ លើការអប់រំ ថែទាំសុខភាព និងថែរក្សាបរិស្ថានធម្មជាតិ ដើម្បីរៀបចំខ្លួនពេញលក្ខណៈជាគ្រីស្តបរិស័ទ ដែលជាពន្លឺដ៏តូចមួយក្នុងសង្គម តែពោរពេញដោយអត្ថន័យ។

លោកក៏មានសេចក្តីសង្ឃឹមថា ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ យុវជន នឹងចេះតស៊ូក្នុងជីវិត ដើម្បីបង្កើតសង្គមថ្មី និងសេចក្តីសង្ឃឹមថ្មី។

យុវជន សិលា ចន្ទ ម៉ានុត មកពីព្រះសហគមន៍កោះស្លា បានឲ្យដឹងថា នេះជាលើកទីមួយដែលបានធ្វើបូជនីយចរនេះ។ យុវជនរូបនេះ បាននិយាយពីបទពិសោធរបស់ខ្លួនធៀបនឹងការអប់រំរបស់លោកអភិបាលថា គាត់ជាមនុស្សដែលមានចិត្តឆេវឆាវ ពិបាកមានចិត្តស្លូតបូត និងមិនដែលចង់ទាមទាររកយុត្តិធម៌សម្រាប់អ្នកណាទេ។ ម៉ានុតបន្តថា កត្តាទាំងនេះហើយធ្វើឲ្យគាត់គ្មានសេចក្តីសុខ។ ម៉ានុតឲ្យដឹងទៀតថា៖ «ពេលដើរខ្ញុំបានទទួលបទពិសោធពីចាស់ៗ នាំឲ្យយល់ថាដំណើរជីវិតរបស់ព្រះជាម្ចាស់គឺអត់ធ្មត់ខ្លាំងណាស់»។

យុវតី សុខ ស្រីមួយ មកពីព្រះសហគមន៍កំពង់ស្ពឺ និយាយថា៖ «ប្រសិនបើយើងចង់ជោគជ័យទៅដល់គោលដៅ គឺកុំជ្រើសរើសភាពងាយស្រួល គឺត្រូវបង្ហាញពីភាពតស៊ូនៅក្នុងជីវិតរបស់យើងម្នាក់ៗ»។

គួរបញ្ជាក់ផងដែរថា នេះជាលើកទី១០ហើយ ដែលយុវជនកាតូលិកភូមិភាគភ្នំពេញរៀបចំកម្មវិធីនេះ ដោយបានចាប់ផ្តើមនៅឆ្នាំ២០១០ នៅតាំងគោក ខេត្តកំពង់ធំ និងលើកទី២ នៅព្រះសហគមន៍ចំណោម ខេត្តបន្ទាយមានជ័យ។ លើកទី៣ នៅក្តុរលើក្នុងខេត្តត្បូងឃ្មុំ។ លើកទី៤ នៅព្រះសហគមន៍តាអំ ខេត្តបន្ទាយមានជ័យ។ លើកទី៥ នៅកំពង់គោ ខេត្តកំពង់ធំ។ លើកទី៦ នៅអរិយក្សត្រ ភ្នំពេញ។ លើកទី៧ នៅបូកគោ ខេត្តកំពត។ លើកទី៨ នៅគីរីវង្ស ខេត្តតាកែវ។ លើកទី៩ នៅតាំងគោក ខេត្តកំពង់ធំ។រីឯឆ្នាំ២០២១ ខាងមុខនេះនឹងធ្វើនៅកសិដ្ឋានឋានសួគ៌ (ភ្នំវល្លិ៍) ខេត្តកែប៕

# វិបត្តិមនុស្សធម៌លើនាវា វេស្ទ័រដាមបានបញ្ចប់ តែពលរដ្ឋហាក់នៅតែដិតដាម នឹងការរីកសាយភាយនៃ មេរោគកូវីដ-១៩



*នាវាវេស្ទ័រដាម ដែលបានចូលចតក្នុងប្រទេសកម្ពុជាកន្លងមក (Westerdam)។* រូបភាព៖ ហ្វេសប៊ុកសម្ដេចនាយករដ្ឋមន្ត្រី

*ដោយ៖ អរិយបុត្រ*

ភាពមន្ទិលសង្ស័យនៃនយោបាយមនុស្សធម៌របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះវិបត្តិមនុស្សធម៌លើនាវាវេស្ទ័រដាម (Westerdam) ដោយសារតែមេរោគ កូវីដ-១៩ (COVID-19) បានបញ្ចប់នៅថ្ងៃទី២១ ខែកុម្ភៈ ក្រោយពេលដែលប្រទេសមួយចំនួនដាក់ការសង្ស័យទៅលើសមត្ថភាពកម្ពុជានៅក្នុងការឆ្លើយតបដោយវិជ្ជមានចំពោះមនុស្សជាង ២០០០នាក់នៅលើនាវាក្រោយរសាត់អណ្ដែតនៅលើសមុទ្ររាប់សិបថ្ងៃ។

ការសង្ស័យនៅលើសមត្ថភាពរបស់កម្ពុជានៅក្នុងការឆ្លើយតបនឹងនយោបាយមនុស្សធម៌ចំពោះមនុស្ស ៤១សញ្ជាតិ ដោយមានអ្នកទេសចរសរុបចំនួន ១.៤៥៥ នាក់ ជាអ្នកទេសចរវ័យចំណាស់ ប៉ុន្តែក៏មានកុមារផងដែរ និងសមាជិកក្រុមនាវិក និងបុគ្គលិកនៅលើនាវានោះសរុបចំនួន ៨០២ នាក់។ នាវានោះបានរសាត់អណ្ដែតនៅលើសមុទ្រចាប់តាំងពីថ្ងៃទី១ ខែ កុម្ភៈ ក្រោយពេលដែលចាកចេញពីទីក្រុងហុងកុង កន្លែងដែលមានអ្នកទេសចរ វ័យចំណាយម្នាក់បានស្លាប់ដោយសារតែមេរោគកូវីដ-១៩ រហូតដល់ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឲ្យចូលចតនៅក្នុងថ្ងៃទី១៣ ខែកុម្ភៈ និង អនុញ្ញាតឲ្យអ្នកដំណើរទាំងអស់ឡើងគោកនៅថ្ងៃទី១៤ ក្រោយពេលដែលត្រូវបានច្រានចោលការស្នើសុំចូលចតដោយប្រទេសជប៉ុន កោះតៃវ៉ាន់ ប្រទេសហ្វីលីពីន កោះហ្គាម និង ប្រទេសថៃ មុនពេលមកដល់កម្ពុជា។

យោងទៅតាមប្រព័ន្ធផ្សព្វផ្សាយបរទេសពីប្រទេសម៉ាឡេស៊ី បានឲ្យដឹងថា លោកស្រី វ៉ាន់ អាហ្សីហ្សាហ្ វ៉ាន់ អ៊ីស្មាអ៊ីល (Wan Azizah Wan Ismail) ឧបនាយករដ្ឋមន្ត្រីនៃប្រទេសនេះ បាននិយាយកាលពីថ្ងៃសុក្រទី២១ខែកុម្ភៈ ថា ស្ត្រីអាមេរិកអាយុ៨៣ឆ្នាំ ដែលបច្ចុប្បន្នកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ នៅក្នុងប្រទេស លោកស្រី ត្រូវបានធ្វើតេស្តម្ដងហើយម្ដងទៀត ហើយលទ្ធផលបានបង្ហាញថា លោកស្រីមិនមានផ្ទុកវីរុសកូវីដ-១៩ នេះទៀតទេ។

ស្ត្រីរូបនេះ និងប្ដីអាយុ៨៥ឆ្នាំរបស់គាត់ ជាសមាជិកនៃក្រុមអ្នកទេសចរជនជាតិអាមេរិកកាំង ដែលបានចាកចេញពីនាវាវេស្ទ័រដាមនៅថ្ងៃទី១នៃថ្ងៃដែលនាវានេះត្រូវបានអនុញ្ញាតឲ្យចូលចតនៅកម្ពុជា ក្រោយពេលដែលត្រូវរុញច្រានចេញដោយប្រទេស៤ និង កោះពីរ។ ប្ដីប្រពន្ធវ័យចំណាស់មួយគូនេះបានហោះហើរតាមជើងហោះហើរពិសេសមួយទៅកាន់ទីក្រុងគូឡាឡាំពួ ដែលមានផ្ទុកអ្នកដំណើរ១៤៥នាក់ ដោយមានតែពួកគេពីរនាក់ប៉ុណ្ណោះ ដែលមានរោគសញ្ញាសង្ស័យថាផ្ទុកមេរោគ កូវីដ-១៩ ទោះបីជាមុនពេលចាកចេញកម្ពុជាបានសហការ យ៉ាងជិតស្និតជាមួយនឹងអង្គការសុខភាពពិភពលោក និង មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ស្ថានទូតពាក់ព័ន្ធ និងផ្នែកផ្សេងៗទៀត តាមរយៈការពិសោធន៍ស្របតាមស្ដង់ដារអន្តរជាតិ។



*សំណាកមេរោគ Covid-19។* រូបភាព៖ បរទេស

ក្រោយការទាមទារពីភាគីកម្ពុជាម្ដងហើយម្ដងទៀត ទាក់ទងនឹងការរកឃើញមេរោគកូវីដ-១៩នៅលើខ្លួនស្ត្រីជនជាតិអាមេរិកាំងរូបនោះ អាជ្ញាធរម៉ាឡេស៊ីបានប្រកាសថា លទ្ធផលពិនិត្យចុងក្រោយគឺស្ត្រីរូបនោះលែងមានមេរោគកូវីដ-១៩ នេះទៀតហើយ។

ក្រោយការប្រកាសនេះ នៅព្រឹកថ្ងៃទី២២ ខែកុម្ភៈ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានចេញនូវសារមួយតាមបណ្ដាញសង្គម។

សម្ដេចតេជោបានសរសេរថា៖ «ការមិនទទួលខុសត្រូវរបស់ជនបរទេសខ្លះលើការពិនិត្យសុខភាពរបស់ភ្ញៀវទេសចរដែលជិះលើនាវាវេស្ទ័ដាម បានធ្វើឲ្យកម្ពុជាក្លាយជាជនរងគ្រោះនៃទង្វើមនុស្សធម៌របស់ខ្លួនអស់រយៈពេលជិតមួយសប្ដាហ៍។ ទេវតាពិតជាមានភ្នែក ពេលនេះអ្វីៗច្បាស់លាស់ហើយដែលកម្ពុជាទទួលបានយុត្តិធម៌មកវិញ។ មិនមានមនុស្សណាម្នាក់ដែលជិះលើនាវាខ្នាតយក្ស វេស្ទ័ដាន ឆ្លងកូវីដ-១៩ នោះទេ»។

ទាក់ទងនឹងសាវតានៃការអនុញ្ញាតឲ្យនាវាទេសចរណ៍វេស្ទ័ដាមនេះចូលចតនៅទឹកដីកម្ពុជា សម្ដេចតេជោ ហ៊ុន សែន បានពន្យល់សាធារណជនម្ដងជាពីរដងថា នេះគឺជាការឆ្លើយតបរបស់កម្ពុជាចំពោះសកម្មភាពមនុស្សធម៌។

ជាការពិត នៅមុនពេលអនុញ្ញាតឲ្យនាវានេះចូលចត នៅគ្រប់ប្រទេសដែលនាវានេះបានស្នើសុំសិទ្ធិចូលចត គឺបានប្រកាសជាបន្តបន្ទាប់ថា គ្មានអ្នកដំណើរ និងបុគ្គលិកណាម្នាក់មានរោគសញ្ញានៃជំងឺផ្ដាសាយ និងរលាកសួតថ្មី ដែលបណ្ដាលមកពីមេរោគកូវីដ-១៩ នេះឡើយ។

ទាក់ទិននឹងបញ្ហាមនុស្សធម៌នេះ សម្ដេចតេជោបានប្រកាសយ៉ាងច្បាស់លាស់ថា ទោះបីជានាវាវេស្ទ័ដាមនេះមានអ្នកជំងឺដែលបង្កដោយមេរោគកូវីដ-១៩ នេះ ក៏កម្ពុជានៅតែអនុញ្ញាតឲ្យនាវានេះចូលចតនៅកម្ពុជាដែរ ដោយសារតែនេះគឺជាសកម្មភាពមនុស្សធម៌។

នៅពេលដែលអញ្ជើញទៅទទួល និងជូនដំណើរដល់ក្រុមអ្នកដំណើរ ដែលត្រូវបានអនុញ្ញាតឲ្យចេញពីនាវាវេស្ទ័ដាម ដំបូងដោយផ្ទាល់ និងបង្ហាញកាយវិការដ៏ស្និទស្នាល ដោយមិនខ្លាចអំពីជំងឺនេះ សម្ដេចតេជោ ហ៊ុន សែន បានប្រកាសថា ប្រសិនជានៅលើនាវានោះមានអ្នកជំងឺបង្កដោយមេរោគកូវីដ-១៩ នេះមែន កម្ពុជានឹងពិចារណាឲ្យនាវានេះចូលចតនៅកម្ពុជាបានកាន់តែលឿន។

ក្រោយពេលដែលនាវានេះត្រូវបានអនុញ្ញាតចូលចត អ្នកដំណើរទាំងអស់នៅលើនាវានេះត្រូវបានអនុញ្ញាតឲ្យ មានសេរីភាព និងទទួលបានការមើលថែទាំយ៉ាងដិតដល់ពីសំណាក់អាជ្ញាធរកម្ពុជា ដោយមិនមានការរើសអើង។ កម្ពុជាបានទទួលការកោតសរសើរពីសំណាក់មេដឹកនាំពិភពលោកមួយចំនួន រួមមានទាំងប្រធានាធិបតីអាមេរិក អគ្គនាយកអង្គការសុខភាពពិភពលោក និង អង្គការទេសចរណ៍ពិភពលោក ព្រមទាំងស្ថាប័ន អន្តរជាតិ និង អ្នកការទូតជាច្រើន ប៉ុន្តែទន្ទឹមនឹងទស្សនៈថា «កម្ពុជាជាប្រទេសតូច តែមានបេះដូងមនុស្សធម៌ធំទូលាយ» ក៏បានលេចឡើង ហើយដាក់ចំណោទសួរវិញដែរ អំពីលទ្ធភាពនៃប្រទេសកម្ពុជានៅក្នុងការទប់ស្កាត់ជំងឺនេះ។

ចម្ងល់និងសំនួរទាំងនេះ ខ្លះក៏បានបញ្ចេញនៅលើបណ្ដាញសង្គម ខ្លះក៏នៅក្នុងក្រុមចង្អៀតនៅលើបណ្ដាញសង្គម ដូចជាក្រុមការងារ ក្រុមមិត្តរួមថ្នាក់ ...។ល។

លោក ឥត ស្នួរមេត្តា ជាប្រជាពលរដ្ឋមួយរូប បានថ្លែងថា រឿងទទួល និងស្វាគមន៍ ក៏ដូចជាសកម្មភាពមនុស្សធម៌ របស់រដ្ឋាភិបាលគឺជារឿងដែលមិនអាចនិយាយបានថាមិនគាំទ្រនោះទេ ដោយសារតែវាគឺជាកាតព្វកិច្ចរបស់មនុស្សជាតិ ហើយគាំទ្រនូវអ្វីដែលអាជ្ញាធរបានធ្វើ។

លោកបានបញ្ជាក់ថា៖ «ឲ្យគ្នាទៅណា បើប្រទេសនេះក៏មិនឲ្យចូល ទៅប្រទេសនោះក៏មិនឲ្យចូល ចឹងមានតែឲ្យមនុស្សជាង២០០០នាក់អណ្ដែតនៅលើសមុទ្រទាល់តែអស់ទឹក អស់បាយ អត់ប្រេងស្លាប់ទាំងអស់គ្នាឬ? ប៉ុន្តែគ្រាន់តែឆ្ងល់ ថាមិនដឹងរដ្ឋាភិបាលគាត់សំអាងអីឲ្យពួកគាត់ដើរទៅនេះទៅនោះ ពេញប្រទេសដោយសេរីបែបនេះ»។

ប្រជាពលរដ្ឋមួយរូបទៀត បានអះអាងនៅហាងកាហ្វេមួយម្ដុំផ្សារទួលទំពូង ហើយអះអាងត្រឹមឈ្មោះថា ជឿន ក៏បានដាក់ចម្ងល់ដែរថា រឿងមនុស្សធម៌ គឺជារឿងមួយ ហើយការអនុញ្ញាតនិងការស្វាគមន៍ពួកគេក៏ជារឿងមួយ ប៉ុន្តែលោកបានដាក់ចម្ងល់មួយថា «ចុះបើពួកគេមានអ្នកផ្ទុក ហើយវាមិនទាន់បញ្ចេញរោគសញ្ញា តើអាជ្ញាធរដោះស្រាយយ៉ាងណា? បើពួកគាត់ត្រូវគេនាំដោយសេរីបែបនេះ? តើយើងមានសមត្ថភាពអាចទប់ស្កាត់ដូចស្រុកគេឬអត់?»។

លោកបន្តទៀតថា៖ «សំណាងហើយ ដែលមិនអី ហើយករណីស្ត្រីអាមេរិកកាំងនៅម៉ាឡេស៊ីក៏មានព័ត៌មានចុងក្រោយថាមិនអីទៀត ចឹងបានយើងធូរទ្រូងច្រើន កុំអី ម្នាក់ៗដេកតែព្រួយហើយ ដោយសារតែរយៈពេលចម្លងនៃមេរោគនេះ គឺព័ត៌មានដែលគេបានចុះជាបន្តបន្ទាប់គឺថា នៅមុនចេញរោគសញ្ញា គឺវាអាចនៅក្នុងខ្លួនមនុស្សរហូតដល់ទៅ១៤ ទៅ ២៤ ថ្ងៃឯណោះ ហើយអ្នកដែលជាហើយក៏នៅអាចមានលទ្ធភាពចម្លងមេរោគនេះទៅអ្នកដទៃទៀតផងដែរ។

ទាក់ទិននឹងករណីនេះមន្ត្រីអ្នកនាំពាក្យក្រសួងសុខាភិបាល បានថ្លែងជាបន្តបន្ទាប់ថា មុននឹងអនុញ្ញាតឲ្យអ្នកដំណើរណាម្នាក់ចេញពីនាវាទេសចរ គឺថា មន្ត្រីសុខាភិបាលបានសហការយ៉ាងជិតស្និតធ្វើការជាមួយនឹងម្ចាស់នាវា មន្ត្រីជំនាញអង្គការសុខភាពពិភពលោក និង មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិកហើយក្រសួងក៏បានបញ្ជាក់ថា មកដល់ពេលនេះ កម្ពុជាក៏នៅមិនទាន់បានរកឃើញករណីនៃការឆ្លងមេរោគ កូវីដ ១៩ នេះ ណាមួយថ្មី និង នៅលើខ្លួនប្រជាពលរដ្ឋកម្ពុជានៅឡើយទេ ប៉ុន្តែនៅតែបន្តព្រមាន និង ផ្សព្វផ្សាយនូវរបៀប និងវិធីសាស្ត្រនៅក្នុងការបង្ការការឆ្លងជំងឺនេះជាបន្តបន្ទាប់។

ក្រោយពេលដែលបានចូលចតនៅកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ អស់រយៈពេល១០ ថ្ងៃពោលគឺចាប់ពីថ្ងៃទី១៣ ដល់ ២២ ខែកុម្ភៈ នាវាវេស្ទ័ដាម បានចាកចេញពីកម្ពុជា ឆ្ពោះទៅកាន់ប្រទេសហ្វីលីពីន និងប្រទេសកំណើតវិញ បន្ទាប់ពីចាក់ប្រេង និងដាក់ស្បៀងរួចរាល់ ខណៈដែលអ្នកទេសចរ ៤១សញ្ជាតិ សរុបជាង ២០០០នាក់បានចាកចេញពីនាវា ឡើងយន្តហោះ ចាកពីកម្ពុជាអស់ហើយ នៅថ្ងៃទី២០ ខែកុម្ភៈ។

តាមតួលេខដែលបានកត់ត្រាអំពីករណីនៃការឆ្លងមេរោគកូវីត១៩ គិតដល់ថ្ងៃទី២២ ខែ កុម្ភៈ ប្រភពពីកាសែត ឆាយណាដេលី បានឲ្យដឹងថា ជនរងគ្រោះដែលឆ្លងជំងឺនេះគឺមានសរុបចំនួន ៧៦.២៨៨ នាក់ ហើយបានសម្លាប់មនុស្សដល់ ២.៣៤៥ នាក់។ មេរោគនេះបានចម្លងនៅប្រទេសប្រមាណជា ជាង៣០ ប្រទេស ហើយ ខណៈដែលពេលនេះក្រៅពីចិន ប្រទេសដែលមានអត្រានៃការឆ្លងកើនឡើងគឺគេសង្កេតឃើញនៅកូរ៉េខាងត្បូង និង ជប៉ុន៕



*សម្ដេចតេជោ ហ៊ុន សែន ថ្លែងទៅកាន់អ្នកធ្វើដំណើរតាមរយៈនាវាវេស្ទ័រដាម ក្រោយពេលត្រូវបានអនុញ្ញាតចូលចត និងអាចធ្វើដំណើត្រឡប់ទៅប្រទេសរៀងៗខ្លួនវិញ។* រូបភាព៖ ហ្វេសប៊ុកសម្ដេចនាយករដ្ឋមន្ត្រី



*ក្រុមឆ្លើយតបបន្ទាន់ និងក្រុមគ្រូពេទ្យដែលបានបណ្ដុះបណ្ដាលអំពីឆ្លើយតបទៅនឹងជំងឺរាតត្បាត។*





*ព័ត៌មានពីការដួលសន្លប់ ត្រូវបានក្លែងបន្លំទៅនឹងជំងឺរលាកសួត Covid-19។* រូបភាព៖ បណ្ដាញសង្គម




*នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង CDC*

# ក្រុមសាសនទូតកេបិក រំលឹកខួប ២៥ឆ្នាំនៃការមកដល់កម្ពុជា

*ដោយ៖ កែវ កញ្ញា*

ក្រុមសាសនទូត កេបិក បានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥ ដោយសហការធ្វើការងារជាមួយព្រះសហគមន៍កម្ពុជាតាមការចាត់តាំងនានា។ ក្រុមនេះបច្ចុប្បន្នមានសមាជិកចំនួន៣នាក់ ក្នុងនោះក៏មានលោកបូជាចារ្យផងដែរ។

លោកបូជាចារ្យពេត្រុ អេមីលីយ៉ូ មានប្រសាសន៍ថា បច្ចុប្បន្នយើងមិនគ្រាន់តែមានបូជាចារ្យប៉ុណ្ណោះទេ គឺមានក្រុមអ្នកស្ម័គ្រចិត្តជាគ្រហស្ថ ដើម្បីបំពេញបេសកកម្មក្រុមនេះ។

លោកបន្តថា បេសកកម្មក្រុម គឺចូលរួមសហការជាមួយសហគមន៍ដើម្បីបង្កើតសហគមន៍សាសនទូត ដោយផ្តោតសំខាន់ទៅលើមនុស្សគ្រប់គ្នា គឺហៅឲ្យបំពេញបេសកកម្មប្រកាសដំណឹងល្អ ដូច្នេះអ្វីដែលយើងធ្វើគឺត្រូវតែចែករំលែកអំណោយទានរបស់យើងម្នាក់ៗក្នុងនាមជាបុត្រធីតារបស់ព្រះជាម្ចាស់ជាមួយអ្នកដទៃ ជាពិសេសអ្នកដែលមិនទាន់ស្គាល់ព្រះយេស៊ូ។

ក្នុងកម្មវិធីកាលពីថ្ងៃទី៨ ខែកុម្ភៈ កន្លងទៅ លោកឪអុវេរ សាបាឡា ជាអ្នកស្ម័គ្រចិត្តនៃក្រុមសាសនទូតកេបិក បានបន្តកិច្ចសន្យាជាមួយក្រុម ដោយមានបេសកកម្មរយៈពេល១០ឆ្នាំបន្តទៀត។




*អភិបូជា និងការចុះកិច្ចសន្យាបន្តការងារស្ម័គ្រចិត្តរបស់លោកឪអុវេរ។* រូបភាព៖ កែវ កញ្ញា

លោកឪអុវេរ បានចូលរួមក្នុងក្រុមគ្រួសារនេះរយៈពេល៦ឆ្នាំមកហើយបានមានប្រសាសន៍ទៀតថា៖ «ខ្ញុំចង់ឆ្លើយតបការត្រាស់របស់ព្រះជាម្ចាស់រយៈពេល១០ឆ្នាំទៀត ពីព្រោះសម្រាប់ខ្ញុំ គឺជឿទុកចិត្តលើព្រះអម្ចាស់ជាមួយអ្វីដែលព្រះអង្គបានអញ្ជើញខ្ញុំឲ្យក្លាយជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះអង្គ ដែលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា»។

លោកបានមកបំពេញបេសកកម្មក្នុងប្រទេសកម្ពុជា៨ឆ្នាំមកហើយ កិច្ចការដែលលោកបានធ្វើ គឺចុះសួរសុខទុក្ខអ្នកជាប់ឃុំនៅពន្ធនាគារ ជាមួយក្រុមគ្រួសារបងប្រុសមេត្តាករុណា និងបង្រៀនភាសាអង់គ្លេសដល់និស្សិតទេវវិទ្យាល័យ។

លោកបានបញ្ជាក់ទៀតថា៖ «ចំពោះខ្ញុំ បេសកកម្មរបស់សាសនទូតគឺការបង្ហាញវត្តមានរបស់ព្រះយេស៊ូនៅក្នុងពិភពលោក ដោយបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គសម្រាប់មនុស្សគ្រប់ជាតិសាសន៍»។ លោកបានបន្តថា ពីព្រោះព្រះយេស៊ូស្រឡាញ់លោក ហើយលោកចង់ប្រាប់ទៅអ្នកដទៃថា ព្រះអង្គក៏ស្រឡាញ់ពួកគាត់ដែរ តាមរយៈវត្តមាន និងការប្តេជ្ញាចិត្តរបស់លោក។

លោកឪអុវេរ សាបាឡា ជាជនជាតិវេណេហ្ស៊ុយអេឡា។ លោកបានចាប់ផ្តើមបេសកកម្មនៅក្នុងទ្វីបអាហ្វ្រិក ហើយបន្ទាប់មកនៅកម្ពុជា។

កញ្ញាប៊ីទ្រីស មីលលេណា ជាប្រធានក្រុមគ្រួសារនេះនៅកម្ពុជា និងបានចូលរួមក្នុងក្រុមនេះអស់រយៈពេល២០ឆ្នាំមកហើយ មានប្រសាសន៍ដែរថា គាត់រីករាយណាស់ចំពោះបេសកកម្មដែលមានសព្វថ្ងៃនេះ។ ស្ត្រីជនជាតិហ្វីលីពីនរូបនេះបន្តថា សព្វថ្ងៃនេះ គាត់ធ្វើការងារនៅក្នុងព្រះសហគមន៍ខេត្តសៀមរាបជាមួយស្ត្រីជាម្តាយរស់នៅតាមភូមិ។

កញ្ញាចូលរួមក្នុងសាសនទូតនេះគឺដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះអ្នកដទៃទៀត។ ហើយក្រុមសាសនទូតបានផ្តល់ការគាំទ្រជាច្រើនដល់រូបគាត់។ «កញ្ញាប៊ីទ្រីស៖ «គេផ្តល់ទាំងអស់ ទាំងកាយទាំងចិត្ត។ ខ្ញុំរីករាយណាស់»។

ក្រុមសាសនទូតកេបិក បង្កើតឡើង នៅក្នុងឆ្នាំ១៩២១ នៅប្រទេសកាណាដា ដែលមានបេសកកម្មចំនួន៨ប្រទេសក្នុងពិភពលោក ជាពិសេសនៅតំបន់អាស៊ីរួមមាន ជប៉ុន កម្ពុជា ហ្វីលីពីន ហុងកុង ប្រេស៊ីល អង់ឌូរ៉ាស់ ពេរ៉ូ និង កេនយ៉ា៕

# បងស្រី សានីសច្ចានិរន្តរ៍

*ដោយ៖ ដាលីស*

បងស្រី តេរ៉េស អេង សានី ជាបព្វជិតា ជាតិកម្ពុជានៃក្រុមគ្រួសារដូនជីឧបការគុណ បានប្រកាសពាក្យសច្ចានិរន្តរ៍ នៅចំពោះមុខព្រះសហគមន៍ទាំងមូល ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ឝ្មីតអីស្លែរ និងបងស្រីម៉ារីអង់ ដែលជាប្រធានក្រុមគ្រួសារឧការគុណនៅព័រស៊ឺ នៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន នាព្រឹកថ្ងៃទី១២ ខែមករាឆ្នាំ២០២០នេះ។

លោកអភិបាលអូលីវីយេមានប្រសាសន៍រំលឹកបងស្រី ឲ្យរក្សានូវពាក្យសន្យាទាំងបីឲ្យបានខ្ជាប់ខ្ជួន គឺរស់នៅលីវមួយជីវិត ស្តាប់បង្គាប់ និងរស់នៅតាមរបៀបជាអ្នកដាក់ខ្លួន។ លោកអភិបាលបានបញ្ជាក់ប្រាប់ថា ព្រះជាម្ចាស់បានគាំទ្រ និងជ្រើសរើសបងស្រី។ បងស្រីត្រូវស្តាប់បង្គាប់បងស្រីប្រធាន ប៉ុន្តែក៏ត្រូវស្តាប់បង្គាប់ព្រះសហគមន៍ដែលជាគ្រួសារដ៏ធំ ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធគឺស្ថិតនៅក្នុងព្រះសហគមន៍ទាំងមូល។

លោកអភិបាលបន្ថែមទៀតថា ការរស់នៅដាក់ខ្លួនជាអ្នកក្រីក្រជារឿងមួយសំខាន់«ដើម្បីធ្វើដំណើរជាមួយអ្នកតូចតាច ដោយធ្វើជាបេះដូងរបស់ព្រះជាម្ចាស់ផ្ទាល់ ជាបេះដូងប្រកបដោយព្រះហឫទ័យប្រណីសន្តោស ដែលជាព្រះឧបការគុណរបស់ព្រះជាម្ចាស់សម្រាប់មនុស្សឯទៀតៗ»។

លោកអភិបាលក៏បានណែនាំឲ្យបងស្រី ចេះចងសម្ពន្ធជាមួយប្រជាជនដោយធ្វើជាពន្លឺនៅក្នុងភាពងងឹត ដោយចេញទៅកន្លែងនានា ដើម្បីជួបជាមួយមនុស្សឯទៀតៗ។

នៅក្នុងពិធី បងស្រី សានី បានសច្ចាដាក់ខ្លួនជាអ្នកក្រីក្រ រក្សាព្រហ្មចារីធម៌ និងស្តាប់បង្គាប់ រួចប្រគល់ពាក្យសច្ចាទៅកាន់បងស្រីប្រធាន និងមានចុះហត្ថលេខានៅលើតុអាសនៈរួមជាមួយ លោកអភិបាល និងបងស្រីប្រធានជាសាក្សី។

បងស្រីសានី បានបញ្ជាក់ថា ជីវិតជាអ្នកបួសសម្រាប់បងស្រីគឺជាការរស់នៅ និងឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដោយប្រកាសថា រស់នៅក្នុងជីវិតជាអ្នកបួស ជាពិសេសក្នុងក្រុមគ្រួសារឧបការគុណ។

បងស្រីបន្តថា ការឆ្លើយតបនេះមិនមែនបញ្ចប់ត្រឹមថ្ងៃនេះទេ គឺបន្តឆ្លើយតបជារៀងរាល់ថ្ងៃ។ បងស្រីបញ្ជាក់ថា «នាពេលអនាគតខ្ញុំក៏មិនទាន់ដឹងច្បាស់ថា បងស្រីប្រធាននឹងចាត់ឲ្យមានបេសកកម្មទៅបម្រើនៅកន្លែងណាឲ្យច្បាស់លាស់នៅឡើយទេ ប៉ុន្តែខ្ញុំចូលចិត្តរស់នៅតាមជនបទបម្រើបងប្អូននៅតាមព្រះសហគមន៍ ជាពិសេសបន្តជំនឿដើម្បីឲ្យបងប្អូនឯទៀតៗ»។

ដូនជីសានីក៏បានអំពាវនាវផងដែរដល់យុវជន យុវនារីឲ្យមានសេចក្តីក្លាហាន និងកុំខ្លាចចំពោះការឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ព្រោះព្រះអង្គគង់នៅជាមួយយើង និងរួមដំណើរជាមួយយើង។




*បងស្រី សានី ប្រគល់ពាក្យសន្យារបស់ខ្លួនដល់បងស្រីប្រធានក្រុមគ្រួសារនៅមុខព្រះសហគមន៍ទាំងមូល។* រូបភាព៖ ស៊ីអេសស៊ី

ក្រុមគ្រួសារឧបការគុណនៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នមានចំនួន ១៩នាក់ដែលចែកជា៣សហគមន៍ គឺនៅភ្នំពេញ( បឹងទំពុន) បាត់ដំបង និងកំពង់ឆ្នាំង។

ដូនជីនៅក្នុងក្រុមគ្រួសារនេះ បានចូលរួមសកម្មភាពទាំងនៅក្នុងព្រះសហគមន៍ ដូចជាកិច្ចការអប់រំជំនឿ សង្គហៈ និងរៀបចំពិធីនានា រីឯកិច្ចការសង្គម មានដូចជា ផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារកំព្រា និងក្រីក្រ ដើម្បីសិក្សារៀនសូត្រ មានមណ្ឌលសម្រាប់កុមារមានពិការភាព បង្កើតសាលារៀននៅតាមសហគមន៍ និងជួយគាំទ្រផ្នែកសុខភាពជាដើម៕





# ព្រះសហគមន៍បាត់ដំបង រំឭកខួប២៣០ឆ្នាំ

រយៈពេល២៣០ឆ្នាំ ព្រះសហគមន៍បាត់ដំបងមានវត្តមាននៅលើទឹកដីនៃខេត្តបាត់ដំបង។ ព្រះសហគមន៍ត្រូវបានរស់រានឡើងវិញ ដោយសារគ្រីស្តបរិស័ទមួយចំនួនតូចដែលនៅសេសសល់ពីរបបប្រល័យពូជសាសន៍ប៉ុល ពតបានមកតាំងលំនៅដើមវិញ។ ប្រជាជនជាច្រើនបានស្គាល់ព្រះសហគមន៍នេះ ហើយហៅឈ្មោះទីតាំងមួយនេះថា ពេទ្យឃាយជី ព្រោះពីដើមឡើយព្រះសហគមន៍នេះ បានទទួលព្យាបាលអ្នកជំងឺទូទៅដែលមានអ្នកមើលថែភាគច្រើនជាដូនជីកាតូលិក។ បេសកកម្មនេះ បានបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ក្នុងខួបទី២៣០ឆ្នាំដែលត្រូវបានធ្វើឡើងក្នុងកាលពីដើមខែមករាកន្លងទៅនេះ លោកអភិបាលអេនរីគេ ហ្វីកាវេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានប្រសាសន៍លើកទឹកចិត្តដល់គ្រីស្តបរិស័ទឲ្យចេះបង្រួបបង្រួមគ្នា ចេះកសាងព្រះសហគមន៍របស់ព្រះជាម្ចាស់ ធ្វើជាសាក្សីនៃសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ដោយចេះអត់ទោសឲ្យគ្នាទៅវិញទៅមក។

ព្រះសហគមន៍បាត់ដំបង មានឧបការិនីគឺព្រះនាងម៉ារី ហើយព្រះវិហារឈ្មោះថាព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ។

លោកអភិបាលបានជំរុញឲ្យគ្រីស្តបរិស័ទយកគំរូតាមព្រះនាងម៉ារីដែលស្រឡាញ់ព្រះយេស៊ូ ជាស្ត្រីសុភាពរាបសារ គ្មានហិង្សា ចេះជួយអ្នកដទៃ និងចេះលើកទឹកចិត្តគេដើម្បីឲ្យគេអាចដើរទៅខាងមុខ។«ព្រះនាងម៉ារីគិតប្រយោជន៍របស់ព្រះជាម្ចាស់ ធ្វើតាមបំណងរបស់ព្រះជាម្ចាស់ មិនសម្រាប់ខ្លួន ( ដូច្នេះ ) យើងត្រូវគិតអំពីប្រយោជន៍រួម និងព្រះសហគមន៍។ ប្រយោជន៍ដែលយើងអាចទៅខាងមុខ»។ លោកអភិបាលបញ្ជាក់គ្រីស្តបរិស័ទ។

លោកអភិបាលមានប្រសាសន៍សូមឲ្យគ្រីស្តបរិស័ទចេះអធិដ្ឋានផ្ទាល់ខ្លួនផង ក្នុងកម្មវិធីបុណ្យនានាផង ដើម្បីចូលជ្រៅទៅក្នុងអត្ថន័យនៃព្រះគម្ពីរ ហើយបញ្ចេញសកម្មភាពដោយជួយអ្នកក្រីក្រអស់ពីចិត្ត ដែលនឹងនាំជំនឿកាន់តែរីកចម្រើនថែមទៀត។

ក្នុងរយៈពេល២៣០ឆ្នាំនេះ ជាអំណោយទានយ៉ាងពិសេសសម្រាប់គ្រីស្តបរិស័ទដែលត្រូវអរព្រះគុណព្រះជាម្ចាស់។ លោកអភិបាលបញ្ជាក់។

លោកអភិបាលអេនរីគេបន្ថែមថា នៅកម្ពុជាយើង ពីមុនមានសង្គ្រាមច្រើន តែដោយសារយើងចេះថែរក្សាជំនឿ ហើយអ្នកដែលនៅសេសសល់បានត្រឡប់មកវិញ ជាហេតុព្រះសហគមន៍បាននៅរស់ដូចសព្វថ្ងៃនេះ។ បច្ចុប្បន្ននេះ យើងគ្មានឧបសគ្គដើម្បីគោរពជំនឿ និងធ្វើសកម្មភាពឡើយ យើងបានបំពេញសកម្មភាពជាច្រើនជាពិសេសនៅក្នុងសង្គមរបស់យើងផ្ទាល់។

ព្រះសហគមន៍បាត់ដំបងជាព្រះសហគមន៍ធំជាងគេក្នុងភូមិភាគបាត់ដំបង ហើយសកម្មភាពដូចជាមានក្រុមគណៈកម្មការសង្គហៈ យុវជន អប់រំជំនឿ ពិធីបុណ្យ ក្រុមចម្រៀង និងមានកម្មវិធីមេត្តាករុណានៅក្នុងសង្គមកម្ពុជា ដូចជាអង្គការមេត្តាករុណា កម្មវិធីចុះតាមភូមិជួយអ្នកក្រីក្រ ឧបត្ថម្ភកុមារឲ្យទទួលបានការសិក្សារៀនសូត្រ កម្មវិធីកុមារអូទីស៊ឹម និងមណ្ឌលសុខភាពជាដើម៕



*គ្រីស្តបរិស័ទថ្លែងក្នុងពិធីរំឭកខួប២៣០ឆ្នាំ។* រូបភាព៖ ព្រះសហគមន៍បាត់ដំបង



*លោកអភិបាលអេនរីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។* រូបភាព៖ ព្រះសហគមន៍បាត់ដំបង



## សម្ពោធអគារបណ្ណាល័យនៅសាលាមត្តេយ្យសន្តិតេរេសា នៅព្រះសហគមន៍ចំណោម

សម្ពោធអគារបណ្ណាល័យនៅសាលាមត្តេយ្យសន្តិតេរេសា នៅព្រះសហគមន៍ចំណោម ដែលជាការឧបត្ថម្ភពីសប្បុរសជនកូរ៉េ ដើម្បីផ្តល់កន្លែងឲ្យកុមារសិក្សាបន្ថែម ពង្រីកចំណេះដឹងតាមរយៈការអានសៀវភៅ។ ពិធីនេះធ្វើឡើងកាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០។





# ព្រះសហគមន៍កំពង់គោនឹងមានព្រះវិហារថ្មី

*ដោយ៖ កែវ កញ្ញា*

គ្រីស្តបរិស័ទជាច្រើននាក់ដែលមកពីតំបន់នានាជិតព្រះសហគមន៍កំពង់គោក្រោម បានជួបជុំគ្នាធ្វើពិធីបញ្ចុះបឋមសិលារបស់ព្រះវិហារសន្តីតេរេសា ស្ថិតក្នុងភូមិកំពង់គោក្រោម ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ក្រោមអធិបតីភាព លោកអភិបាល អេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងរួមនិងលោកបូជាចារ្យជាច្រើនអង្គ និងអាជ្ញាធរដែនដី កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២០។

លោកញ៉ឹល សារិទ្ធជាគ្រីស្តបរិស័ទចំណុះវិហារនេះមានប្រសាសន៍ថា ព្រះវិហារថ្មីនេះធ្វើឲ្យគាត់សប្បាយចិត្ត ដោយបានរំលឹកគាត់អំពីអតីតកាល។

លោក សារិទ្ធ៖ «កាលពីខ្ញុំនៅតូចធ្លាប់មានព្រះវិហារមួយ ហើយដល់ពេលខ្លួនខ្ញុំធំឡើង មានសង្គ្រាម វាអត់ព្រះវិហារ ហើយដល់ពេលចាស់ទៅ ឃើញព្រះវិហារមានវិញ ហាក់បីដូចខ្លួននៅក្មេងវិញ មើលទៅវាដូចនៅឈិបៗ វាអត់ឃ្លាតឆ្ងាយ។ ហើយមានកម្លាំងឡើងវិញ ហាក់បីដូចខ្លួនហ្នឹងមានអារម្មណ៍សប្បាយដូចនៅពីក្មេងអីចឹង»។

លោកសារិទ្ធបន្ថែមថា គាត់ចង់ឲ្យយុវជននៅក្នុងព្រះសហគមន៍ទាំងអស់ ចេះមើលគំរូរបស់ចាស់ទុំ ដើម្បីសេចក្តីសុខ។ លោក សារិទ្ធបានថ្លែងថា៖ «ភាពសុខសាន្ត ភាពសុខដុមរមនារបស់ចាស់ពីដើម ដោយសារគាត់ឡើងវិហាររាល់ថ្ងៃអាទិត្យ ហើយគាត់សួរសុខទុក្ខគ្នារាល់ថ្ងៃអាទិត្យ»។

យុវនារី ម៉ៅ សាវៀត ជាអ្នកគ្រូបង្រៀនសាលាមត្តេយ្យរបស់ព្រះសហគមន៍ និងជាគ្រូអប់រំជំនឿ មានប្រសាសន៍ថា នាងមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំងដែលនឹងមានព្រះវិហារធ្វើអំពីថ្មក្នុងពេលឆាប់ៗនេះ។ សាវៀត៖ «យើងបានព្រះវិហារថ្មនេះហើយ យើងនឹងចូលរួមហាត់ ហើយធ្វើឲ្យសំឡេងរបស់យើងពីរោះជាងមុន»។

អ្នកគ្រូ សាវៀត បានឲ្យដឹងទៀតថា ក្នុងតំបន់កំពង់គោក្រោមយុវជនភាគច្រើនគឺជាកូនចៅគ្រីស្តបរិស័ទ។ ក្នុងនោះព្រះសហគមន៍មានកម្មវិធីមួយចំនួនដើម្បីប្រមូលពួកគាត់ឲ្យមកព្រះវិហារ។ សាវៀត៖ «ពួកខ្ញុំតែងតែមានកម្មវិធី ហាត់ចម្រៀងរួមគ្នា និងមានប្រជុំយុវជន ហើយពេលខ្លះយើងមានពេលវេលា ថ្ងៃណាសម្រាក យើងមានកម្មវិធីដើរលេងកំសាន្តជាមួយគ្នា ដើម្បីយើងបង្កើតបរិយាកាស ដើម្បីទាក់ទាញយុវជន ព្រោះយុវជនទាំងនេះសុទ្ធតែជាកូនចៅគ្រីស្តបរិស័ទ។ ប្រសិនបើយើងអត់បានធ្វើចំណាប់អារម្មណ៍ឲ្យគេ អត់បានប្រមូលគេទេ គឺគេបែកគំនិតអស់»។

សាវៀត និយាយថា កិច្ចការបម្រើព្រះសហមន៍គឺបានធ្វើឲ្យនាងមានជំនឿ និងសប្បាយចិត្ត។

លោកបូជាចារ្យ ម៉ាក លូប៉េស ជាអ្នកទទួលខុសត្រូវនៅព្រះសហគមន៍តំបន់កំពង់ធំទាំងមូល មានប្រសាសន៍ថា ទីតាំងនៃដីរបស់ព្រះវិហារនេះ គឺជាដីសក្ការៈដែលព្រះសហគមន៍គោរពតាំងពីដើមមក ដែលមានប្រវត្តិ១០០ឆ្នាំមកហើយ។



*លោកអភិបាល អេនរីគេ ហ្វីការេដូ ក្នុងពិធីបញ្ចុះបឋមសិលា។ រូបភាព៖ ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង*

សព្វថ្ងៃនេះគ្រីស្តបរិស័ទបានប្រារព្ធពិធីបុណ្យនានានៅក្នុងព្រះវិហារធ្វើអំពីឈើ។ ពេលមានព្រះវិហារថ្មី អាគារនោះនឹងក្លាយជាកន្លែងសម្រាប់រៀបចំកម្មវិធីអប់រំជំនឿ និងសុខភាពសម្រាប់ព្រះសហគមន៍វិញម្តង។ នេះបើតាមសម្តីរបស់លោកម៉ាក។

ព្រះវិហារសន្តីតេរេសាថ្មីនឹងមានទំហំ ១២គុណនឹង២០ម៉ែត្រ ហើយនឹងមានអាសនៈរបស់ប្រារព្ធពិធីនៅកណ្តាលព្រះវិហារ។

លោកម៉ាក ពន្យល់ថា៖ «ដើម្បីពេលថ្វាយអភិបូជាបងប្អូននឹងអង្គុយមិនមែននៅខាងមុខអសនៈទេ គឺអង្គុយនៅទាំងខាងស្តាំដៃ និងឆ្វេងដៃ និងខាងមុខ»។ លោកបូជាចារ្យបន្ថែមថា យើងទទួលវត្តមានរបស់ព្រះជាម្ចាស់តាមរយៈព្រះកាយព្រះគ្រីស្ត ហើយក៏តាមរយៈវត្តមានគ្រីស្តបរិស័ទដែលមកជួបជុំគ្នា «គេមើលមុខគ្នា និងសង្ឃឹមថាគេញញឹម ហើយគេមានអារម្មណ៍ថាយើងជាគ្រួសារធំតែមួយ»។

លោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងមានប្រសាសន៍ថា ព្រះវិហារថ្មីនេះ គឺជាការចូលក្នុងប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍ដែលយើងចាប់ផ្តើមមានជីវិតថ្មី។ លោកអភិបាលបន្តថា៖ «ព្រះសហគមន៍កំពង់គោមានជីវិត និងនាំឲ្យព្រះសហគមន៍ដទៃមានជីវិតដែរ ទាំងនៅក្នុងសង្គមកម្ពុជា និងបរទេស។ ព្រះសហគមន៍កំពង់គោ មានសកម្មភាពច្រើន កូនក្មេងច្រើន គណៈកម្មការសកម្ម យុវជនបានទៅស្រុកគេ ព្រះសហគមន៍មានជីវិតមែនទែន»។

លោកអភិបាលបានរំលឹកថា នៅពេលមានព្រះវិហារថ្មី សូមឲ្យគ្រីស្តបរិស័ទកាន់ជំនឿតាមរបៀបល្អសមរម្យ ដោយចូលរួមយ៉ាងសកម្មសម្រាប់ភូមិស្រុកអភិវឌ្ឍ មានកិត្តិយស និងជីវិតដ៏ល្អ ដោយចៀសវាងចំណាកស្រុកទៅភូមិស្រុកដទៃ។

លោកអភិបាលបានលើកឡើងថា៖ «ខ្ញុំអរណាស់ៗ ដោយសារ ខ្ញុំឃើញគណៈកម្មការសប្បាយ រួបរួមគ្នា លោករួមគ្នា និងខ្ញុំមានជំនាន់ថ្មីដោយមានរបៀបថ្មី។ យើងចាប់ផ្តើមជីវិតថ្មី ឆ្នាំ២០២០នេះ»។

សព្វថ្ងៃព្រះសហគមន៍កំពង់គោមានចំនួន៦៨គ្រួសារគ្រីស្តបរិស័ទ ដែលមានសកម្មភាពជាច្រើនដូចជា សាលាមត្តេយ្យថ្នាក់បង្រៀនបំប៉នសិស្សបឋមសិក្សា ការការពារបរិស្ថាន ឡាដាវតូស៊ី មណ្ឌលសន្តប្រ៉ង់ស៊ីស្កូ កម្មវិធីពិនិត្យសុខភាព៕



ព្រះវិហារព្រះត្រៃឯក

ព្រះសហគមន៍កាតូលិក
ភូមិព្រៃជើង ឃុំគោកព្រិច
ស្រុកគិរីវង់ ខេត្តតាកែវ







*ព្រះវិហារសន្តប៉ូលនៅព្រះសហគមន៍បាវិត ខេត្តស្វាយរៀង។ រូបភាព៖ ឆាក លាំង*



*ជើងតាំងព្រះកាយជាអំណោយរបស់លោកអភិបាលប៊្រុយណូ សម្រាប់ព្រះវិហារថ្មី។ រូបភាព៖ កែវ កញ្ញា*

# លោកអភិបាល៖ ជីវិតគ្រីស្តបរិស័ទផ្ទាល់ ជាព្រះវិហារ និងទីសក្ការៈរបស់ព្រះជាម្ចាស់

*ដោយ៖ កែវ កញ្ញា*

គ្រីស្តបរិស័ទមកពីទីជិតឆ្ងាយក្នុង និងក្រៅប្រទេសកម្ពុជា បានជួបជុំគ្នាប្រមាណជិត១០០០នាក់ ដើម្បីធ្វើពិធីបុណ្យឆ្លងព្រះវិហារសន្តប៉ូល ស្ថិតនៅក្នុងក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ក្រោមអធិបតីភាពរបស់លោកអភិបាលប៊្រុយណូ កូសម៍ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ដោយមានការចូលរួមពីលោកបូជាចារ្យនិងអ្នកបួសជាច្រើននាក់។



*រូបថតអនុស្សាវរីយ៍៖ លោកបូជាចារ្យឡាយប៉ូល បងស្រីម៉ារីអាឡែន លោកអភិបាលប៊្រុយណូនិងគ្រីស្តបរិស័ទ។*

មុនពេលចាប់ផ្តើមកម្មវិធីថ្វាយអភិបូជា លោកអភិបាល បូជាចារ្យ និងគ្រីស្តបរិស័ទបានដង្ហែបីជុំព្រះវិហារ។ បន្ទាប់មកលោកអភិបាលប៊្រុយណូបានប្រគល់សោរព្រះវិហារជូនលោកបូជាចារ្យឡាយ ប៉ូលដែលជាអ្នកទទួលខុសត្រូវព្រះសហគមន៍នេះ ហើយលោកបានអញ្ជើញគ្រីស្តបរិស័ទទាំងអស់ចូលក្នុងវិហារថ្មី និងបន្តកម្មវិធីអធិដ្ឋាន។

លោក ប៊្រុយណូ កូសម៍ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមមានប្រសាសន៍ក្នុងធម្មទេសនាក្នុងថ្ងៃបើកព្រះវិហារថ្មីនេះថា កាលពីដើម ព្រះវិហារដែលជនជាតិយូដាបានសាងសង់ ដើម្បីគោរពថ្វាយបង្គំព្រះជាម្ចាស់ គឺជាអគារធំ ប៉ុន្តែនៅខាងក្នុងគឺទទេ។ ប៉ុន្តែពេលព្រះយេស៊ូយាងមកព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះវិហារគឺនៅក្នុងខ្លួនយើង ហើយយើងគោរពព្រះជាម្ចាស់នៅទីណាក៏បាន គឺជាទីសក្ការៈ។ យើងជាដំណាក់របស់ព្រះជាម្ចាស់។

លោកអភិបាលបានបញ្ជាក់ទៀតថា យើងជាគ្រីស្តបរិស័ទក៏មាននូវកន្លែងមួយទៀតដែលយើងអាចជួបព្រះជាម្ចាស់ផ្ទាល់ខ្លួន គឺព្រះវិហារ។ ជាហេតុព្រះសហគមន៍មានព្រះវិហារជាអគារ «ប៉ុន្តែជាមួយព្រះយេស៊ូ យើងដឹងថា ព្រះវិហាររបស់យើង អគាររបស់យើងមិនមែនសុទ្ធតែជាថ្ម។ ជាថ្ម ប៉ុន្តែជាថ្មមានជីវិត គឺយើងផ្ទាល់ ដែលកសាងព្រះវិហាររបស់ព្រះជាម្ចាស់»។

លោកអភិបាលប៊្រុយណូ បន្ថែមថា តាមរយៈវត្តមានរបស់យើង តុសក្ការៈ លោកបូជាចារ្យ និងអគ្គសញ្ញានីមួយៗព្រះជាម្ចាស់គង់នៅក្នុងកណ្តាលចំណោមយើង។

លោកបន្តថា៖ «ម្យ៉ាងមានចំណុច ២ដ៏សំខាន់ យើងគោរពកន្លែងនេះ (ព្រះវិហារថ្មី) និងយើង(ក៏)គោរពកន្លែងរបស់យើង(ដែលជា) ទីសក្ការៈរបស់យើង គឺជីវិតផ្ទាល់របស់យើងជាគ្រីស្តបរិស័ទ ក្រុមគ្រួសាររបស់យើង ក៏ជាកន្លែងដែលយើងអាចជួបព្រះជាម្ចាស់បានដែរ»។

លោកបូជាចារ្យឡាយ ប៉ូល ជាអ្នកទទួលខុសត្រូវព្រះវិហារសន្តប៉ូលនៅបាវិតមានប្រសាសន៍ថា អគារព្រះវិហារថ្មីនេះមានទំហំ ទទឹង១២ម៉ែត្រ និងបណ្តោយ៣០ម៉ែត្រ ដែលអាចផ្ទុកមនុស្សបានជាច្រើនរយនាក់ផងដែរ។

លោកបានប្រាប់ឲ្យដឹងថា សព្វថ្ងៃគ្រីស្តបរិស័ទដែលមកចូលរួមថ្វាយអភិបូជារៀងរាល់ថ្ងៃអាទិត្យគឺភាគច្រើនជាកម្មករ និងជាងសំណង់ ដែលមានភាគច្រើនជាជនជាតិវៀតណាម និងមានខ្លះជាជនជាតិហ្វីលីពីន។

លោកបូជាចារ្យទទួលខុសត្រូវបានរៀបរាប់អំពីប្រវត្តិនៃព្រះសហគមន៍នេះថា ក្នុងឆ្នាំ១៩៩៩ លោក អន់តូនីសាមីស៊ូសែរាជ្យ អតីតជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងបងស្រី អាឡាំង បានដើរប្រមូលគ្រីស្តបរិស័ទ មានត្រឹមតែ២-៣គ្រួសារប៉ុណ្ណោះ ហើយពួកគេរស់នៅឆ្ងាយៗពីគ្នាដោយសុំផ្ទះរបស់គេជួបជុំគ្នាអធិដ្ឋាន។ ក្រោយមកក៏សុំធ្វើជាខ្ទមតូចមួយដើម្បីជួបជុំគ្នាលើដីរបស់គេដដែល ហើយចំនួនគ្រីស្តបរិស័ទកាន់តែកើនឡើងបន្តិចម្តងៗ។

ក្នុងឆ្នាំ២០០៩ នៅពេលលោកប៉ូលទទួលខុសត្រូវ ចំនួនគ្រីស្តបរិស័ទក៏ចេះតែកើនឡើងច្រើនជាងមុន។ លោកបូជាចារ្យរូបនេះបន្តថា៖ «បានប្រហែល២-៣ឆ្នាំ យើងក៏ចាប់ផ្តើមរកដី។ សំណាង យើងរកដីនេះបាន យើងក៏កសាងកូនព្រះវិហារប័ង្កសីមួយតូចដែរដើម្បីចាប់ផ្តើម»។

លោកប៉ូលបន្ថែមថា៖ «រាល់អាទិត្យ យើងមានកើនឡើងប្រហែលជិត៨០ ទៅដល់១០០ជាង ដែលនាំឲ្យយើងរិះគិត អត់កើត។ កូនព្រះវិហារយើងវាក្តៅ ហើយវាចង្អៀត ដូច្នេះយើងក៏សុំច្បាប់ជួសជុល ដោយគ្រីស្តបរិស័ទចូលរួមទាំងជិតឆ្ងាយ។... តាមសទ្ធាតាមសមត្ថភាព ខ្លះ១០០០ (ដុល្លារ) ខ្លះ៥០០(ដុល្លារ) ខ្លះ៥០ (ដុល្លារ) ខ្លះ២០(ដុល្លារ)»។

ព្រះវិហារសន្តប៉ូលនេះ គ្រីស្តបរិស័ទមានសកម្មភាព ដូចជាសកម្មភាពសង្គហៈដោយដើរសួរសុខទុក្ខចាស់ជរា និងអ្នកជំងឺតាមផ្ទះ និងសកម្មភាពឧបត្ថម្ភកុមារឲ្យទៅរៀន។ លោកបូជាចារ្យបានឲ្យដឹងទៀតថា ទោះបីមានចំនួនគ្រីស្តបរិស័ទច្រើនក៏ពិតមែន ប៉ុន្តែគ្រីស្តបរិស័ទមិនសូវមានពេលវេលាដើម្បីចូលរួមក្នុងសកម្មភាពព្រះសគមន៍នោះទេ ពីព្រោះតែកិច្ចការរកស៊ី និងម្យ៉ាងវិញទៀត ពួកគាត់រស់នៅឆ្ងាយៗពីគ្នា។

គម្រោងទៅអនាគតសម្រាប់ទីតាំងថ្មីនេះ ព្រះសហគមន៍ចង់បង្កើតកម្មវិធីអប់រំសម្រាប់កុមារតូចៗដែលឪពុកម្តាយរបស់គេ មិនអាចមើលថែ និងអប់រំកុមារនៅផ្ទះបាន ដោយមានឡានទៅទទួលពួកគេមកសិក្សាទាំងអប់រំទូទៅ និងអប់រំជំនឿ។

លោកបូជាចារ្យប៉ូលឲ្យដឹងថា៖ «ទៅអនាគត យើងគិតអំពីកុមារ អំពីការសិក្សារបស់កុមារ។ យើងមានការលំបាកធំនៅទីនេះ គឺកុមារតូចៗខ្វាត់ខ្វាយមែនទែន។ ឪពុកម្តាយទៅធ្វើការអស់ គេទុក(កូន)ដូចពាសពេញស្រុកខ្មែរ។ គេទុក(កូន)ឲ្យយាយនៅផ្ទះ ហើយយាយនៅឆ្ងាយក៏ពិបាកនាំមក»។

នៅលើដីរបស់ព្រះសហគមន៍នេះក៏មាននូវអគារសម្រាប់ធ្វើសកម្មភាពនានារបស់ព្រះសហគមន៍ដែលមានទំហំ ទទឹង១០ម៉ែត្រ និងបណ្តោយ ២៤ម៉ែត្រ។ លោកបូជាចារ្យ ឡាយ ប៉ូលបន្តថា អគារនោះសម្រាប់លោកបូជាចារ្យស្នាក់នៅ មានបន្ទប់ប្រជុំធំមួយ ឬអាចធ្វើជាបន្ទប់សាលាមត្តេយ្យ និងមានបន្ទប់អប់រំជំនឿ ឬកន្លែងស្នាក់នៅរបស់ភ្ញៀវជាដើម៕

# លោកអភិបាលប្រកាសឆ្នាំនៃការប្រកាសដំណឹងល្អ២០២០-២០២២

*ដោយៈ ដាលីស*

លោកអភិបាល អូលីវីយេ ជ្មិតអីស្លែរ បានមានប្រសាសន៍ថា ក្នុងឆ្នាំ២០២០-២០២២ ព្រះសហគមន៍ភូមិភាគភ្នំពេញ រួមនឹងព្រះសហគមន៍នៅតំបន់អាស៊ីនឹងធ្វើដំណើររួមគ្នា ដោយផ្ដោតសំខាន់លើគោលដៅរួម គឺប្រកាសដំណឹងល្អ។ ក្នុងរយៈពេល ៣ឆ្នាំខាងមុខនេះ ព្រះសហគមន៍កម្ពុជាត្រូវយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការប្រកាសដំណឹងល្អ ដោយបម្រើអ្នកក្រីក្រ សន្ទនាជាមួយសាសនានានា និងរស់នៅក្នុងវប្បធម៌នៃជាតិសាសន៍របស់ប្រទេសកម្ពុជា។

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍នេះ នៅក្នុងជំនួបប្រចាំឆ្នាំជាមួយក្រុមបុគ្គលិកការិយាល័យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទាំងអស់ នាថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ស្ថិតក្នុងសង្កាត់ភ្នំពេញថ្មី ក្នុងរាជធានីភ្នំពេញដែលមានអ្នកចូលរួមប្រមាណជាង៥០នាក់។




*លោក អូលីវីយេ ជ្មិតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ រូបភាពៈ ស៊ីអេសស៊ី*

លោកអភិបាលបានរំលឹកថា សម្រាប់ ៣ ឆ្នាំខាងមុខ ការិយាល័យនីមួយៗត្រូវចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរួម ដែលនឹងមានគឺ «រួមដំណើររួមគ្នាជាមួយប្រជាជាតិអាស៊ី» ដែលមាន ៣០ប្រទេសនៅក្នុងទ្វីបអាស៊ី ស្ថិតក្រោមអភិបាលកិច្ចរបស់ក្រុមលោកអភិបាលចំនួន១៧ ប្រទេស ដើម្បីប្រកាសដំណឹងល្អ ដល់ប្រជាជនក្នុងតំបន់ ដោយយកខ្លឹមសារឯកសាររបស់សន្តសម្ដេចប៉ាបយ៉ូហានប៉ូលទី២ ដែលបានណែនាំព្រះសហគមន៍នៅទ្វីបអាស៊ី ជាមូលដ្ឋានក្នុងការអនុវត្ត។

លោកមានប្រសាសន៍ក្នុងធម្មទេសនាថា អ្វីៗទាំងអស់ដែលយើងធ្វើបាន លុះត្រាតែយើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រភពនៃកម្លាំងដួងចិត្ត ហើយអគ្គទស្សនៈគឺជាអ្វីដែលចេញពីដំណឹងល្អរបស់ព្រះជាម្ចាស់។ ដូចនេះព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនទៅណាឆ្ងាយពីជីវិតប្រចាំថ្ងៃរបស់យើងឡើយ។

ក្នុងជំនួបនេះដែរ លោកអភិបាលបានជំរុញឲ្យការិយាល័យទាំងអស់យកចិត្តទុកដាក់ផងដែរអំពីប្រព័ន្ធគ្រប់គ្រង និងរបៀបនៃការទំនាក់ទំនងគ្នានៅក្នុងការិយាល័យផ្ទាល់ និងជាមួយស្ថាប័នកាតូលិកនានាផងដែរ។

លោកបានសង្កត់ធ្ងន់ចំនួន ១០ចំណុចគឺ៖ ១-សន្ទនាជាមួយបូជាចារ្យគ្រប់មណ្ឌលសកម្មភាព។ ២-វាយតម្លៃផលប៉ះពាល់ចំពោះកិច្ចការដែលបានធ្វើ។ ៣-ធ្វើរបាយការណ៍ប្រចាំខែ។ ៤-ប្រជុំប្រចាំខែដើម្បីលើកទឹកចិត្តគ្នាទៅវិញទៅមក និងរកដំណោះស្រាយ។ ៥-ធ្វើរបាយការណ៍ហិរញ្ញវត្ថុច្បាស់លាស់ និងមានតម្លាភាព។ ៦-ចូលរួមជាមួយនឹងព្រឹត្តិការណ៍នានាដែលមាននៅក្នុងភូមិភាគភ្នំពេញ។ ៧-មានពេលវេលាដើម្បីសំណាក់ធម៌ រិះគិតអំពីជំនឿ និងកិច្ចការប្រកាសដំណឹងល្អ។ ៨-បន្តធ្វើការងារដោយមានកំលាំង។ ៩-ជ្រើសរើសព័ត៌មានដែលត្រូវផ្សព្វផ្សាយ និង ១០-ថែរក្សាអគ្គទស្សនៈរបស់យើង។

កិច្ចជួបជុំនេះបានធ្វើជារៀងរាល់មួយឆ្នាំក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត ដើម្បីលើកទឹកចិត្ត និងស្គាល់គ្នារវាងការិយាល័យក្នុងព្រះសហគមន៍ ដោយមានការណែនាំពីលោកអភិបាល អភិបូជា និងទទួលអាហារសាមគ្គី។

ការិយាល័យដែលបម្រើការងារឲ្យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញដែលបានចូលរួមនៅក្នុងកម្មវិធីនេះមានដូចជា ការិយាល័យយុវជនកុមារ និងគ្រួសារ ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ការិយាល័យសុខភាព ការិយាល័យអប់រំជំនឿ និងព្រះគម្ពីរ ការិយាល័យអប់រំសិក្សា ការិយាល័យពលករ ការិយាល័យលោកអភិបាល ក្រុមស្វាគមន៍នៅភ្នំពេញថ្មី ការិយាល័យសហគ្រិនសង្គម និងការិយាល័យសិល្បៈ៕

# លោកអភិបាលអូលីវីយេ ស្នើឲ្យគ្រីស្តបរិស័ទយកវីរបុរសខ្មែរធ្វើជាគំរូ

*ដោយៈ ដាលីស*



លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ជ្មិតអីស្លែរ បានស្នើដល់គ្រីស្តបរិស័ទ និងអស់លោកដែលជាបព្វជិត បព្វជិតា មានតួនាទីបម្រើព្រះសហគមន៍កាតូលិក មណ្ឌលសកម្មភាពមេគង្គ ឲ្យយកចិត្តទុកដាក់បម្រើអ្នកតូចតាច ដោយយកគំរូតាមវីរបុរសខ្មែរ ក្នុងឱកាសប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន-វៀតណាម កាលពីថ្ងៃទី២៦ កុម្ភៈ ២០២០ នៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយ៉េ ដោយមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

នៅក្នុងធម្មទេសនានៃកម្មវិធីបុណ្យអភិបូជាចូលឆ្នាំថ្មីនេះដែរ លោកអភិបាលអូលីវីយេបានមានប្រសាសន៍អប់រំគ្រីស្តបរិស័ទទាំងអស់ ជាពិសេសបព្វជិតបព្វជិតា ដែលរស់នៅលើទឹកដីកម្ពុជា ដោយយកវីរភាពរបស់ព្រះបាទជយវរ្ម័នទី៧ជាគំរូ ព្រោះព្រះអង្គ បានបង្ហុបបង្រួមប្រជារាស្ត្រឲ្យមានសន្តិភាពក្នុងជំនឿសាសនា ជាមហាក្សត្រដែលចេញក្រៅរាជវាំងទៅសួរសុខទុក្ខប្រជារាស្ត្រ កសាងហេដ្ឋារចនាសម្ពន្ធ ដើម្បីអភិវឌ្ឍគ្រប់វិស័យ និងមន្ទីរពេទ្យដែលជាសកម្មភាពមេត្តាករុណាសម្រាប់រាល់មនុស្សតូចតាចនៅក្នុងសង្គម។



*លោក អូលីវីយេ ជ្មិតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ ស៊ីអេសស៊ី*

លោកអភិបាលបញ្ជាក់ទៀតថា សូមឲ្យយើងចេះបើកភ្នែកមើលវីរបុរសខ្មែរ និងសន្តសន្តីធ្វើជាគំរូ ដើម្បីរស់នៅក្នុងសេចក្ដីសុខដែលមានព្រះជាម្ចាស់គង់នៅ និងមានសេចក្ដីសង្ឃឹមតទៅមុខទៀត លុះត្រាតែយើងចាក់ឫសនៅក្នុងការអធិដ្ឋាន និងសូត្រធម៌។

នៅក្នុងឆ្នាំថ្មីនេះដែរ ក្រៅពីការណែនាំខាងលើ លោកបានបន្ថែមទៀតថា នៅក្នុងឆ្នាំថ្មីនេះ សូមបងប្អូនយកចិត្តទុកដាក់ជាមួយក្រុមគ្រួសារ ស្រឡាញ់ក្រុមគ្រួសារផ្ទាល់ខ្លួន និងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។

លោកបន្តទៀតថា ដោយសូមឲ្យក្មេងៗស្ដាប់បង្គាប់ឪពុកម្ដាយ ហើយឪពុកម្ដាយក៏ត្រូវយល់ពីក្មេងៗវិញផងដែរ ដើម្បីឲ្យគ្រួសារមានសេចក្ដីសុខសុភមង្គល៕









*លោកអូលីវីយេ ជាអធិបតីក្នុងពិធីអភិបូជា បញ្ចុះបឋមសិលាកសាងសសរតម្កល់ជួងថ្មីនៅព្រះវិហារព្រះត្រៃឯកនៃព្រះសហគមន៍កាតូលិកភូមិព្រៃជើង ឃុំគោកព្រិច ស្រុកគិរីវង់ ខេត្តតាកែវ។ រូបភាពៈ ស៊ីអេសស៊ី*

# ព្រះសហគមន៍គិរីវង់កសាងសសរតម្កល់ជួងថ្មី

*ដោយៈ លី សុវណ្ណា*

*លោកអូលីវីយេ ជ្មិតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានអញ្ជើញ ជាអធិបតីក្នុងពិធីអភិបូជា បញ្ចុះបឋមសិលា កសាងសសរតម្កល់ជួងថ្មី នៅព្រះវិហារព្រះត្រៃឯក នៃព្រះសហគមន៍កាតូលិកភូមិព្រៃជើង ឃុំគោកព្រិច ស្រុកគិរីវង់ ខេត្តតាកែវ នាព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២០នេះ។*

តាមប្រពៃណីរបស់គ្រីស្តសាសនា គេប្រើជួង ដើម្បីហៅ ឬផ្ដល់សញ្ញាដល់គ្រីស្តបរិស័ទទាំងអស់អំពីពេលវេលាប្រារព្ធពិធីផ្សេងៗ ការអធិដ្ឋាន អភិបូជាជាដើម។ ពេលខ្លះការបន្លឺសំឡេងជួងក៏ជាជំនឿមួយសម្រាប់ការដេញវិញ្ញាណអាក្រក់ផងដែរ។

ពេលខ្លះគ្រវីយជួងក្នុងពេលប្រារព្ធពិធីបុណ្យ ដើម្បីជាសញ្ញាអបអរសាទរ និងលើកតម្កើងព្រះជាម្ចាស់។ គ្រីស្តសាសនា បានប្រើជួងនៅក្នុងអំឡុងឆ្នាំ៤០០ នៃគ្រិស្តសករាជ។ នៅឆ្នាំប្រមាណ ៦០២ មានការទទួលស្គាល់ និងអនុញ្ញាតពីសម្ដេចប៉ាប ក្នុងការប្រើប្រាស់ជួង។ សតវត្សក្រោយៗមកក៏ពេញនិយមនៅអឺរ៉ុបខាងជើង ហើយបន្តមករហូតបច្ចុប្បន្ន។

នៅសម័យមុនសង្គ្រាមស៊ីវិល ព្រះវិហារកាតូលិកនៅកម្ពុជាទាំងអស់មានបំពាក់ជួង ដើម្បីងាយស្រួលក្នុងការប្រមូលគ្រីស្តបរិស័ទមកចូលរួមពិធីបុណ្យនៅព្រះវិហារ។ ព្រះវិហារទាំងនោះត្រូវបានបំផ្លាញចោលអស់ ជួងមួយចំនួនត្រូវគេឃើញដាក់តាំងនៅក្នុងសារមន្ទីរជាតិ។ ព្រះសហគមន៍រស់ឡើងវិញក្រោយសង្គ្រាម។ សព្វថ្ងៃនេះ មានមូលហេតុផ្សេងៗ ព្រះវិហារកាតូលិកនៅកម្ពុជាខ្លះ មិនទាន់មានបំពាក់ជួងនោះទេ។

ព្រះសហគមន៍គិរីវង់ ចាប់ផ្ដើមកកើតឡើងនៅឆ្នាំ២០០៣ ខណៈដែលលោកបូជាចារ្យអូលីវីយេ បានទៅដល់ភូមិព្រៃជើង ដែលអ្នកជាច្រើនគិតថា លោកជាគ្រូពេទ្យបារាំង។ នេះបើតាមការលើកឡើងរបស់លោកអភិបាលអូលីវីយេទៅកាន់បងប្អូនក្នុងធម្មទេសនា។

លោកបញ្ជាក់ថា តាមពិត មានលោកចយ និងបងប្អូនខ្លះ បានទៅឈ្វេងយល់អំពីព្រះសហគមន៍កាតូលិក និងទទួលអប់រំជំនឿមុនឆ្នាំ២០០៣ នៅព្រះសហគមន៍កាតូលិកភូមិចំការទៀង។ ពេលលោកបូជាចារ្យអូលីវីយេ បានមកដល់និងបន្តកិច្ចអប់រំជំនឿ បន្តិចម្ដងៗមានបងប្អូនទទួលអគ្គសញ្ញាជ្រមុជទឹក និងបានចាត់ចែងកសាងព្រះវិហារ នៅជាប់ជើងភ្នំ នៅលើដីដែលគេគិតថាជាដីអារ មិនអាចធ្វើកសិកម្ម។ ប៉ុន្តែទឹកដីនោះ បានក្លាយជាព្រះវិហារដ៏រឹងមាំ និងបានដំណើរការកម្មវិធីនានាដើម្បីការអប់រំ និងការប្រកាសដំណឹងល្អដល់បច្ចុប្បន្ននេះ។



*ទិដ្ឋភាពនៃព្រះសហគមន៍គិរីវង់។ រូបភាពៈ ស៊ីអេសស៊ី*

តាមប្រសាសន៍របស់លោកហ្វេណាន់ដូ បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍មួយនេះ បានឲ្យដឹងថា ព្រះសហគមន៍គិរីវង់ សព្វថ្ងៃមានគ្រីស្តបរិស័ទប្រមាណ១០០នាក់ មានអ្នកឈ្វេងយល់ជំនឿថ្មី ចំនួន១២នាក់ និងអ្នកដែលកំពុងត្រៀមខ្លួនទទួលជំហានទី១ ( ពិធីចូលព្រះសហគមន៍) ចំនួន២០នាក់។ លោកបូជាចារ្យបន្តថា ព្រះសហគមន៍មានសកម្មភាពជាប្រចាំ គឺកិច្ចការបម្រើអ្នកក្រីក្រ មានក្រុមសង្គហៈ កម្មវិធីសុខភាពដែលមានគ្រូពេទ្យពីភ្នំពេញទៅពិនិត្យជំងឺ១ខែម្ដង និងការជូនអ្នកជំងឺទៅមន្ទីរពេទ្យជាដើម ក្រៅពីនេះ ក៏មានសកម្មភាពអប់រំ មានសាលាមត្តេយ្យ មានក្រុមកាយឫទ្ធិជាដើម។

លោកបូជាចារ្យបញ្ជាក់ថា៖ «កិច្ចការអប់រំជំនឿជាយុទ្ធសាស្ត្រដែលព្រះសហគមន៍បានយកចិត្តទុកដាក់ជាចំណុចអាទិភាពតែម្ដង»។

ក្នុងធម្មទេសក្នុងថ្ងៃប្រារព្ធពិធីអភិបូជា បញ្ចុះបឋមសិលានោះ លោកអភិបាល បានពញ្ញាក់ស្មារតីគ្រីស្តបរិស័ទ ឲ្យចេះសម្រេចចិត្ត រកឃើញផ្លូវនៃសុភមង្គល និងសេចក្ដីសុខសាន្ត។ ព្រះជាម្ចាស់បានផ្ដល់សេរីភាពឲ្យមនុស្សមានការសម្រេចចិត្តក្នុងការជ្រើសរើស។ តែព្រះអង្គមិនសព្វព្រះហឫទ័យមនុស្សណាម្នាក់វិនាសឡើយ។ លោកបញ្ជាក់៖ «ជីវិតរបស់យើងត្រូវតែជ្រើសរើសផ្លូវមួយ។ ត្រូវរិះគិតពីមួយថ្ងៃទៅមួយថ្ងៃ ម្នាក់ៗត្រូវការជ្រើសរើសផ្លូវអ្វីខ្លះ ដើម្បីឲ្យជីវិតរបស់ខ្លួនរីកចម្រើន ក្នុងសេចក្ដីសុខសាន្ត និងសុភមង្គល»។

លោកបញ្ជាក់ថា ទោះជ្រើសយកផ្លូវដើម្បីសេចក្ដីសុខ តែក៏មិនត្រូវមានចិត្តអាត្មានិយមឡើយ គឺត្រូវចែករំលែកជាមួយបងប្អូនឯទៀត ដើម្បីបងប្អូនអាចរស់នៅក្នុងសេចក្ដីសុខសាន្ត សុភមង្គល និងរីកចម្រើន។

ជាចុងក្រោយលោកអភិបាល បញ្ជាក់ឲ្យបងប្អូនទៅជាមនុស្ស ឬគ្រីស្តបរិស័ទសកម្ម ដោយខិតខំបំពេញកិច្ចគ្រប់យ៉ាងដោយយកចិត្តទុកដាក់ និងអស់ពីសមត្ថភាព ទាំងការសិក្សា ការគោរពចាស់ទុំ សម្រាប់យុវជនយុវនារី និងបម្រើបងប្អូនសម្រាប់គ្រីស្តបរិស័ទទាំងអស់។

បន្ទាប់ពីអភិបូជា លោកអភិបាលនិងគ្រីស្តបរិស័ទទាំងអស់ បានធ្វើដំណើរទៅដល់កន្លែងចាក់គ្រឹះសាងសង់សសរតម្កល់ជួង ដោយលោកអភិបាល លោកបូជាចារ្យ និងចាស់ទុំនៃព្រះសហគមន៍ដាក់ថ្ម ខ្សាច់ស៊ីម៉ង់ក្នុងរណ្ដៅគ្រឹះ បន្ទាប់មកលោកអភិបាលប្រោះទឹកព្រះពរ លើគ្រីស្តបរិស័ទ និងទីកន្លែងនោះទាំងមូលតាមជំនឿកាតូលិក៕



*ពិធីអភិបូជាដើម្បីអរព្រះគុណព្រះជាម្ចាស់ នូវជើងជួងថ្មី។ រូបភាពៈ ស៊ីអេសស៊ី*



*លោកអភិបាលប្រោះទឹកព្រះពរដល់យុវជន ក្នុងពេលអភិបូជា។ ស៊ីអេសស៊ី*

# លោកអភិបាលជំរុញ គ្រីស្តបរិស័ទឲ្យយកចិត្តទុកដាក់អ្នកក្រីក្រ អរិយធម៌ ធម្មជាតិនិងព្រះសហគមន៍

*ដោយៈ ង៉ែត សុធីរិទ្ធ*

មុនរដូវអប់រំពិសេស ឬរដូវត្រណមខាងមុខនេះ លោកអភិបាលអូលីវីយេ បានជំរុញឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់នូវបួនចំណុចសំខាន់ៗ ទាក់ទងទៅនឹងអ្នកក្រីក្រ អរិយធម៌ប្រពៃណីក្នុងប្រទេស ការថែរក្សាធនធានធម្មជាតិ និងការអភិវឌ្ឍព្រះសហគមន៍ក្នុងរបៀបថ្មីមួយ។

លោកអភិបាលមានប្រសាសន៍អំពីរឿងទាំងនេះនៅក្នុងធម្មទេសនានៅព្រះសហគមន៍សន្តិសិលា ពោធិ៍ធំ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២០នេះ ដោយភ្ជាប់សារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ។

លោកអភិបាលមានប្រសាសន៍ថា៖ «កុំឲ្យយើងមានសង្គមដែលបែងចែកមនុស្ស...ឲ្យសិទ្ធិមនុស្សមានភាពស្មើគ្នាសម្រាប់មនុស្សទាំងអស់»។ លោកអភិបាលបន្ថែមថា ទោះបីព្រះសហគមន៍យើងតូចក៏ដោយ នៅពេលយើងលើកទឹកចិត្តជាមួយអ្នកក្រីក្រ ជាមួយកម្មករ ជាមួយអ្នកជំងឺ ជាមួយបងប្អូនដែលសង្គមមិនអើពើ យើងដឹងថា នៅពេលនោះ យើងចូលនៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ មានន័យថា យើងបានធ្វើដំណើរជាមួយអ្នកក្រីក្រដើម្បីឲ្យមនុស្សទាំងអស់មានជីវិតថ្លៃថ្នូរ និងមានសិទ្ធិស្មើៗគ្នា «នេះជាសំឡេងដែលព្រះសហគមន៍អាចមាន»។

ក្នុងនោះដែរ លោកអភិបាលបានជំរុញឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតនៅក្នុងរដូវអប់រំពិសេសថ្ងៃខាងមុខនេះ ចំពោះអ្នកក្រីក្រ ដែលកំពុងរស់សង្ឃឹម និងបាត់បង់តម្លៃថ្លៃថ្នូរក្នុងជីវិត។

ក្នុងនោះដែរលោកអភិបាលបានរំលឹកថា ព្រះសហគមន៍នៅកម្ពុជា មិនមែនជាព្រះសហគមន៍របស់បរទេសទេ ប៉ុន្តែផ្ទុយទៅវិញព្រះសហគមន៍នេះភ្ជាប់ជីវិត អំណរសប្បាយ ទុក្ខលំបាក ប្រពៃណីវប្បធម៌សាសនា របៀបដែលប្រជាជនកម្ពុជារស់នៅជាប្រចាំ «ដើម្បីឲ្យព្រះហឫទ័យរបស់ព្រះគ្រីស្តចូលនៅក្នុងទឹកដីរបស់យើងយ៉ាងជ្រៅ និងធ្វើដំណើរជាមួយបងប្អូនយ៉ាងពិតប្រាកដ»។

លោកអភិបាលបន្ថែមថា របៀបដែលយើងអធិដ្ឋានរបៀបដែលយើងបង្កើតទំនាក់ទំនង របៀបដែលយើងចូលនៅក្នុងបុណ្យប្រពៃណីនីមួយៗ... នេះជារបៀបដែលបង្ហាញថា យើងជាគ្រួសារតែមួយដែលចេះគោរពគ្នាទៅវិញទៅមក ដែលចេះទទួលប្រពៃណីអរិយធម៌ វប្បធម៌ដ៏អស្ចារ្យ ដើម្បីចូលនៅក្នុងពន្លឺរបស់ព្រះគ្រីស្តផង។

ពាក់ព័ន្ធនឹងបរិស្ថាន លោកអភិបាលបានជំរុញឲ្យគ្រីស្តបរិស័ទរួមគ្នាថែរក្សាធម្មជាតិ ដែលព្រះជាម្ចាស់បានបង្កើតមកសម្រាប់ជីវិតរស់នៅរបស់មនុស្ស។ «ពេលយើងអស់ព្រៃឈើ ពេលយើងអស់សត្វ យើងគ្មានអ្វីដើម្បីចិញ្ចឹមជីវិតរបស់យើងទៀតទេ ឲ្យយើងស្រឡាញ់ធម្មជាតិរបស់យើង។ សព្វថ្ងៃ នៅក្នុងទន្លេយើងនេសាទបានត្រីតិចទៅៗ នេះដោយសារលទ្ធផលនៃរបៀបដែលយើងរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដែលណែនាំឲ្យយើងបំផ្លាញធម្មជាតិ» លោកអភិបាលបញ្ជាក់។

លោកអភិបាលមានប្រសាសន៍សូមឲ្យគ្រីស្តបរិស័ទចាត់ទុកផែនដីនេះជាផ្ទះរួមរបស់យើងទាំងអស់គ្នា ហើយមនុស្សទាំងអស់ជាក្រុមគ្រួសារមួយដែលចេះស្រឡាញ់ផ្ទះរួមនេះ។

មុននឹងបញ្ចប់ធម្មទេសនា លោកអភិបាលក៏ជំរុញឲ្យគ្រីស្តបរិស័ទចូលរួមបន្ថែមទៀត ដើម្បីបង្កើតសកម្មភាពនានាក្នុងព្រះសហគមន៍ រួមមាន សង្គហៈ និងក្រុមអប់រំបន្តជំនឿជាដើម។

ជាមួយកិច្ចការបម្រើព្រះសហគមន៍ក្នុងមុខងារជាអ្នកបួស លោកអភិបាលបានជំរុញឲ្យយុវជន-នារីចូលរួមថ្វាយខ្លួនដើម្បីបម្រើព្រះសហគមន៍ ដើម្បីឲ្យព្រះសហគមន៍ក្លាយជារបៀបខ្មែរពិតៗ និងរស់នៅក្នុងអរិយធម៌ និងវប្បធម៌នៃជាតិសាសន៍ខ្មែរ៕

# រស់នៅជាមិត្តសម្លាញ់ព្រះគ្រីស្ត ត្រូវធ្វើយ៉ាងណា?





*អង្គសន្និបាតយុវជនតំបន់បាត់ដំបង ដែលរៀបចំដោយក្រុមយុវជន។ រូបភាពៈ ព្រះសហគមន៍បាត់ដំបង*

*ដោយៈ កែវ កញ្ញា*

«អ្នករាល់គ្នាជាមិត្តសម្លាញ់របស់ខ្ញុំ» ជាប្រធានបទនៅក្នុងអង្គសន្និបាតយុវជនតំបន់បាត់ដំបង ដែលមានយុវជនចូលរួមជិត២០០នាក់មកពីតំបន់ផ្សេងៗក្នុងខេត្តបាត់ដំបង។

កម្មវិធីនេះ បានរៀបចំឡើងដោយក្រុមយុវជន ដើម្បីរិះគិតរួមគ្នាអំពីធ្វើយ៉ាងណាដើម្បីឲ្យយុវជនក្លាយជាមិត្តសម្លាញ់របស់ព្រះយេស៊ូគ្រីស្ត និងអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះបើយោងតាមការពន្យល់របស់លោកបូជាចារ្យទម្លាប់ សុផល ជាអ្នកទទួលខុសត្រូវយុវជននៅតំបន់បាត់ដំបង។

លោកបូជាចារ្យបានបន្ថែមថា ទិសដៅសំខាន់ក្នុងសន្និបាតនេះគឺឲ្យយុវជនស្គាល់ព្រះយេស៊ូ រស់នៅតាមរបៀបព្រះយេស៊ូ និងចេញទៅប្រកាសដំណឹងល្អ។ លោកបូជាចារ្យបញ្ជាក់ថា គឺយើងឲ្យយុវជនគិតថា ខ្លួនឯងគឺដូចយុវជនផ្សេងៗនៅក្នុងសង្គម។ ពួកគាត់ទៅរៀន មានជីវិតរស់នៅដូចយុវជនដទៃ ប៉ុន្តែមួយជំហានទៀតគាត់មានព្រះជាម្ចាស់ គឺវាខុសគ្នាត្រង់ចំណុចហ្នឹង(ជាមួយយុវជនក្នុងសង្គម) ហើយរបៀបនៃការរស់នៅគឺខុសគ្នាថែមទៀត ដើម្បីក្លាយជាយុវជនគ្រីស្តបរិស័ទ។

លោកបូជាចារ្យរូបនេះបន្តថា ក្រោយពេលស្គាល់ខ្លួនឯងជានរណាត្រូវស្គាល់អំពីជំនឿរបស់ខ្លួន ដើម្បីក្លាយជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។ «ក្នុងព្រះសហគមន៍អ្នកឯងត្រូវរស់យ៉ាងម៉េច? ទាំងការទៅចូលរួមអភិបូជា តើជាកាតព្វកិច្ចដែលត្រូវទៅឬខ្ញុំស្រឡាញ់ ហើយចង់ទៅ? ហើយខ្ញុំចង់ចូលរួមក្នុងសកម្មភាពព្រះសហគមន៍ដោយចិត្តចង់ ឬក៏គិតថាមានគេគ្រប់គ្រងហើយ មិនចាំបាច់ខ្លួនទៀតទេ? ឬមួយរស់នៅគ្រាន់តែចាក់ចុចព្រះសហគមន៍។ មានអ្នកណាអត់ពេញចិត្តអីរឿងលោក ខ្ញុំនិយាយថែមឲ្យខ្លាំង ឲ្យព្រះសហគមន៍វាឆេះឡើង? ទាំងនេះ គួរសួរខ្លួនឯង» លោកបូជាចារ្យបន្ថែម។

លោកបានជំរុញយុវជនទាំងអស់រិះគិតបន្ថែមទៀត ដើម្បីចូលរួមក្នុងសកម្មភាពព្រះសហគមន៍ដោយចិត្តស្រឡាញ់និងចង់ឲ្យព្រះសហគមន៍រីកចម្រើន ហើយលោកបានហៅចំណុចរៀបរាប់ខាងលើថា «ជាចំណុចអសកម្ម»។

លោកបានលើកឡើងទៀតថា ព្រះជាម្ចាស់បានឲ្យយើងធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គ។ ព្រះគ្រីស្តត្រូវការយើងរហូត។ «ព្រះគ្រីស្តអត់ដែលប្រាប់ព្រះបិតាថា ព្រះបិតាត្រូវការកូនទេ? គឺព្រះអង្គដឹងតែពីធ្វើតាមព្រះហឫទ័យព្រះបិតា» លោកបូជាចារ្យសង្កត់ធ្ងន់យ៉ាងនេះ។ លោកបន្ថែមថា «យើងមានឱកាសយើងធ្វើ យើងមានឱកាសយើងឆ្លើយ យើងកុំនៅរាត់ៗ ហើយធ្វើឲ្យមានការបាក់បែកថែមទៀត។ ផ្ទុយទៅវិញយើងនៅស្ងៀម ហើយសួរខ្លួនឯងថា ខ្ញុំត្រូវផ្តើមដោយអី?»

ក្នុងមេរៀនជាច្រើនរយៈពេលពីរថ្ងៃកាលពីថ្ងៃទី៧-៨ ខែមករា នៅព្រះសហគមន៍បាត់ដំបង យុវជនបានរៀនផងដែរ អំពីការចូលរួមក្នុងសង្គមក្នុងនាមជាយុវជនគ្រីស្តបរិស័ទ និងការប្រកាសដំណឹងល្អដល់យុវជនផ្សេងៗទៀត។

លោកបូជាចារ្យទម្លាប់ សុផល បន្ថែមថា ព្រះយេស៊ូបានយកឱកាសតូចតាច ដើម្បីបង្រៀនសិស្សរបស់ព្រះអង្គ។ ព្រះអង្គមិនចាប់កំហុសដោយសាររឿងវិន័យឡើយ គឺព្រះអង្គបំភ្លឺគេ ទាំងជនជាតិយូដា និងគ្រីស្តទូតដែលជាមិត្តសម្លាញ់របស់ព្រះអង្គ។ ព្រះអង្គមិនបានប្រឆាំង គឺមានរបៀបសុភាពរាបសារ។ ដូច្នេះ យើងសួរខ្លួនឯងថា តើយើងមានចិត្តសុភាពរាបសារប៉ុណ្ណាក្នុងពេលរស់នៅជាមួយមិត្តភក្តិ?

លោកបូជាចារ្យបានពន្យល់ទៀតថា សព្វថ្ងៃនេះ យុវជនគិតតែអំពីរឿងផ្ទាល់ខ្លួន ទាំងសម្ភារនិយម ភាពចង់មានចង់បានសម្រាប់ខ្លួនឯងប៉ុណ្ណោះ។ លោកបានលើកជាសំណួរថា តើសមទេ ដែលយើងធ្វើដូច្នេះ? «ម៉ែឪយើងធ្វើអី? មានលុយប៉ុណ្ណា? ហើយគាត់តស៊ូប៉ុណ្ណាដើម្បីចិញ្ចឹមយើង ប្អូនយើងបងយើងគ្រប់សព្វ?» លោកបន្ថែម។

លោកសុផល លើកឡើងទៀតថា យុវជនគួរតែពេញចិត្តនូវអ្វីដែលខ្លួនមាន និងរស់តាមរបៀបរបស់ព្រះយេស៊ូ គឺរបៀបតូចតាចដែលព្រះអង្គមាន និងបានធ្វើ ដើម្បីទទួលបានសេចក្តីសុខទាំងផ្លូវកាយនិងចិត្ត។ លោកបញ្ជាក់ថា «ខ្ញុំមិនត្រូវការទាមទារឡើយ មានអានេះទៀត មានអានោះទៀតរហូត នោះខ្ញុំនឹងធ្វើបាបខ្លួនខ្ញុំផ្ទាល់ ដោយរកសេចក្តីសុខអត់ឃើញ ដោយខ្វល់គិតធ្វើអីខ្លះដើម្បីបានអាហ្នឹង ហេតុអ្វីគេបាន ហេតុអីអញអត់បាន? ហើយចាប់ផ្តើមរុកគួនម៉ែឪ ឬមួម៉ៅដាក់បងប្អូនក្នុងផ្ទះ ឬមិត្តភក្តិដែលខ្លួនឯងនៅជាមួយ។ល។ ទាំងអស់ហ្នឹងបងប្អូនត្រូវគិត មិត្តសម្លាញ់ព្រះគ្រីស្តរស់បែបហ្នឹងមិនងាយស្រួលទេ តែបងប្អូនត្រូវតែមានស្មារតីរស់ជាមិត្តសម្លាញ់ព្រះគ្រីស្តពិតប្រាកដ»។

ចុងក្រោយនៃអង្គសន្និបាត លោកបូជាចារ្យឲ្យយុវជនរិះគិត និងសម្រេចចិត្តរស់នៅបែបណា ដើម្បីប្រែរបៀបរស់នៅឲ្យកាន់តែជិតស្និទ្ធជាមួយមិត្តសម្លាញ់គឺព្រះគ្រីស្ត និងកុំឲ្យមានគម្លាតឆ្ងាយពីព្រះអង្គ។ លោកបូជាចារ្យរំលឹក «កុំឲ្យឃ្លាតឆ្ងាយពីគាត់ឬធ្វើឲ្យមិត្តសម្លាញ់របស់ខ្ញុំអាប់កិត្តិយស។ ដូច្នេះយើងត្រូវរក្សាព្រះបន្ទូលឲ្យនៅក្នុងខ្លួនជានិច្ច»៕





# ព្រះសហគមន៍ចែកអំណរសប្បាយជាមួយជនជាប់ឃុំនៅកំពត

*ព្រះសហគមន៍កាតូលិកតំបន់កំពត នៃភូមិភាគភ្នំពេញ បានរៀបចំពិធីសំណេះសំណាល អបអរសាទរបុណ្យព្រះយេស៊ូប្រសូតជាលក្ខណៈសាសនា ជាមួយជនជាប់ឃុំចំនួន ៩៧៤ នាក់នៅពន្ធនាគារខេត្តកំពត នាព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ ២០២០ ក្រោមអធិបតីភាពរបស់លោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រះគ្រូធម្មចរិយាមុនី ចាន់ សុវណ្ណ ព្រះមេគុណគណៈធម្មយុត្តិនិកាយខេត្តកំពត លោកប្រធានគណៈអ៊ីម៉ាំខេត្ត ព្រះសង្ឃ លោកបូជាចារ្យ លោកគ្រូគង្វាល និងបរិស័ទនៃសាសនាទាំងអស់យ៉ាងច្រើនកុះករ។*



លោកអភិបាលអូលីវីយេ ប្រោះព្រំទឹកមន្តដល់អ្នកជាប់ឃុំ។ *រូបភាពៈ លី សុវណ្ណា*

*ដោយៈ លី សុវណ្ណា*



*ព្រះគ្រូធម្មចរិយាមុនី ចាន់ សុវណ្ណ ព្រះមេគុណគណៈធម្មយុត្តិនិកាយខេត្តកំពត។ រូបភាពៈ លី សុវណ្ណា*

មានមតិស្វាគមន៍ក្នុងពិធីសំណេះសំណាលនេះ លោក តាវ៉ូឡា យ៉ាំងលូកា បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពកំពតបានមានប្រសាសន៍ថា ព្រះសហគមន៍មានអំណរសប្បាយទទួលស្វាគមន៍បងប្អូនគ្រប់សាសនាមកសួរសុខទុក្ខ បងប្អូនជាប់ឃុំ ដើម្បីអបអរសាទរបុណ្យព្រះយេស៊ូប្រសូត និងដើម្បីចែករំលែកអំណរសប្បាយ សេចក្តីស្រលាញ់ ដែលមកពីព្រះយេស៊ូ និងមកពីព្រះជាម្ចាស់។ លោកបន្តថា វត្តមានរបស់បងប្អូនទាំងអស់ ពិសេសណាស់ ដើម្បីរួមគ្នាកសាងសុខសន្តិភាព ខិតខំកាន់ដៃរួមជាមួយគ្នា ដើម្បីសេចក្តីសុខសុខដុមរមនា រស់នៅប្រកបដោយសេចក្តីស្រលាញ់ សន្តិភាព សេចក្តីសុខសាន្ត និងរួបរួមគ្នាជាធ្លុងតែមួយ។

ព្រះសហគមន៍កាតូលិកខេត្តកំពតបានរៀបចំចូលសួរសុខទុក្ខបងប្អូនជាប់ឃុំក្នុងពន្ធនាគារខេត្ត ក្នុងឱកាសបុណ្យព្រះយេស៊ូតាំងពីឆ្នាំ២០០៩មកម្ល៉េះ ផ្តួចផ្តើមគំនិតដោយលោកបូជាចារ្យអូលីវីយេ។ ក្នុងឆ្នាំ ២០១០ បានរៀបចំពិធីសំណេះសំណាល ជាលក្ខណៈអន្តរសាសនា ដោយលោកបូជាចារ្យអ៊ុន សុន។ រហូតមកដល់ពេលនេះមានចំនួន ១៦ លើកហើយ។

តាមរយៈរបាយការណ៍របស់លោក វរៈអគ្គានុរក្សថ្នាក់លេខ១ អ៊ិន រៀម អនុប្រធានពន្ធនាគារខេត្តកំពត បានឲ្យដឹងថា អ្នកជាប់ឃុំទាំងអស់មានចំនួន ៩៧៤នាក់ ក្នុងនោះស្ត្រីមានចំនួន ៣៨ នាក់ មានជនបរទេស ចំនួន ២០ នាក់ និងមានអ្នកកាន់សាសនាឥស្លាមចំនួន ៣៥នាក់។

ក្នុងពិធីដ៏មានអត្ថន័យនេះ ព្រះគ្រូធម្មចរិយាមុនី ចាន់ សុវណ្ណ ព្រះមេគុណគណៈធម្មយុត្តិនិកាយខេត្តកំពត មានសង្ឃដីការលើកទឹកចិត្ត និងរំលឹកដល់បងប្អូនជាប់ឃុំទាំងអស់ អំពីសីល៥ក្នុងព្រះពុទ្ធសាសនា ដែលជាការអប់រំរបស់ព្រះពុទ្ធសម្រាប់មនុស្ស អាចរស់នៅប្រកបដោយសេចក្តីសុខ មានដូចជា៖ បាណាតិបាតា គឺវៀរចាកការសម្លាប់ជីវិត។ អទិន្នាទា គឺវៀរចាកការលួចទ្រព្យ។ កាមេសុមិច្ឆាចារា គឺវៀរចាកកាមកិច្ចខុសបវេណី។ មុសាវាទា គឺវៀរចាកការភូតកុហក។ សុរាមេរយៈ គឺវៀរចាកការសេពសុរា ឬទឹកស្រវឹងផ្សេងៗ ។ លោកថា ប្រសិនបើបងប្អូនខិតខំប្រព្រឹត្តនូវចំណុចទាំងប្រាំនេះបាន គឺបងប្អូនមិនមានទុក្ខនោះទេ ជាពិសេសគឺ «ត្រូវជៀសឲ្យឆ្ងាយពីគ្រឿងញៀន»។ ព្រះគ្រូបានសម្តែងនូវទឹកចិត្តសង្ឃឹមជានិច្ចថាបងប្អូនជាប់ឃុំទាំងអស់និងខិតខំកែប្រែខ្លួន ដើម្បីក្លាយជាពលរដ្ឋល្អ ពេលចេញទៅវិញ។

ចំណែកលោក ប្រធានគណៈអ៊ីម៉ាំខេត្តកំពតមានប្រសាសន៍ថា មនុស្សម្នាក់ៗរស់ក្នុងលោកនេះ គឺមានបំណងរស់នៅដោយសុខសន្តិភាព សិទ្ធិសេរីភាព និងសុភមង្គល។

លោកបន្តទៀតថា សិទ្ធិសេរីភាព សុភមង្គល អាស្រ័យលើបុគ្គលម្នាក់ៗជាអ្នកកសាងឡើង ដូចអល់ឡោះបានបញ្ជាក់ ក្នុងគួរអានថាឥរិយាបទរបស់មនុស្សអល់ឡោះមិនកែប្រែទេ ដរាបណាតែមនុស្សកែប្រែឥរិយាបទទៅតាមការទូន្មាន របស់ច្បាប់នៃសង្គមជាតិឬសាសនាដោយខ្លួនឯង។

លោកប្រធានគណៈអ៊ីម៉ាំ បានបញ្ជាក់ថា តាមគោលការណ៍សាសនាឥស្លាម បើអ្នកទាំងឡាយណាបានធ្វើរាល់កំហុសឆ្គងដោយចេតនាឬអចេតនា ទោះបីកំហុសធំប៉ុណ្ណាក៏ដោយឲ្យតែបុគ្គលនោះព្រមទទួល និងកែប្រែមកធ្វើល្អវិញពិតណាស់អល់ឡោះលើកលែងរាល់កំហុសឆ្គងឬបាបដែលបានធ្វើកន្លងមកនោះ ហើយសង្គមក៏ដូច្នេះដែរ។ មហាម៉ាត់បានមានប្រសាសន៍ថាពេលណាមនុស្សម្នាក់ស្លាប់ ហើយការចូលរួមដង្ហែសពទៅស្មសាន មាន៣ក្រុម ដែលរួមដំណើរទៅជាមួយ មានដូចជា ក្រុមគ្រួសារសាច់ញាតិនៃសព។ ទ្រព្យសម្បត្តិ និងផលបុណ្យដែលល្អនិងអាក្រក់។ ក្រោយពេលបញ្ចុះសពរួចមាន ២ក្រុម ដែលវិលត្រឡប់មកវិញគឺ ក្រុមគ្រួសារសាច់ញាតិនៃសព និង ទ្រព្យសម្បត្តិរីឯក្រុមដែលទៅជាមួយសពគឺផលបុណ្យ និងផលបាបតែប៉ុណ្ណោះ។ លោកបានក៏ជំរុញលើកទឹកចិត្តឲ្យបងប្អូនជាប់ឃុំគិតពិចារណា កសាងខ្លួនរកផ្លូវធ្វើល្អឡើងវិញ។



*លោកអភិបាលបានជូនពរបងប្អូនជាប់ឃុំ និងមានការតស៊ូ កែប្រែចិត្តគំនិត។ រូបភាពៈ លី សុវណ្ណា*

ក្នុងពិធីដ៏មានសារៈសំខាន់ និងមានអត្ថន័យនេះលោកអូលីវីអភិបាលព្រះសហគមន៍កាតូលិកមានប្រសាសន៍សំណេះសំណាលជាមួយបងប្អូនទាំងអស់ថា ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រី ដែលជាកំពូលនៃស្នាព្រះហស្តរបស់ព្រះអង្គ ហើយព្រះអង្គបានបង្កើតអ្វីៗទាំងអស់លើផែនដីនេះទាំងផ្ទៃមេឃ សត្វដើម្បីឲ្យមានសេចក្តីសុខ សុភមង្គល និងសុខដុមរមនា។ មនុស្សចូលក្នុងគំរោងការនេះ ដើម្បីរស់នៅក្នុងសេចក្តីសុខ ដើម្បីរស់នៅក្នុងសុខដុមរនា។

លោកបានរំលឹកដល់បងប្អូនថា សូមគិតពិចារណា ដែលគ្រប់គ្នាមានពេលវេលា ដើម្បីគិត ផ្ទាល់ខ្លួនថា ខ្ញុំចូលក្នុងគំរោងការនៃការបង្កើតពិភពលោក ខ្ញុំជាបុរស ខ្ញុំជាស្ត្រី គិតពិចារណា ដើម្បីខ្ញុំប្រើសេរីភាពរបស់ខ្ញុំក្នុងរបៀបត្រឹមត្រូវ។ លោកក៏បានលើកយកសុភាសិតខ្មែរមួយ «ខ្លួនទីពឹងខ្លួន» ហើយតាមភាសាបារាំង «ខ្លួនជួយខ្លួនឯង ព្រះជាម្ចាស់នឹងជួយតាមក្រោយ»។ លោកបន្តថា យើងមិនត្រឹមតែពឹងលើខ្លួនឯងប៉ុណ្ណោះទេ។ ពឹងខ្លួនឯង មានព្រំដែនក្នុងសេរីភាពរបស់យើង។ ដូចខ្លែងឯក ដែលមានខ្សែពឹងឲ្យហោះឡើងខ្ពស់។ បើដាច់ខ្សែ គឺខ្លែងនឹងធ្លាក់។ លោកបញ្ជាក់ថា ជីវិតយើងសំខាន់ សេរីភាព ត្រូវតែពឹងលើ សីល៥។ ពឹងលើធម្មវិន័យចេះស្រលាញ់គ្នាទៅវិញទៅមក ដូចស្រលាញ់ខ្លួនឯង ព្រោះព្រះជាម្ចាស់ស្រលាញ់យើង។ ពឹងលើបងប្អូនឯទៀតៗ។ ពឹងលើសង្គម ដើម្បីរស់នៅដោយជួយគ្នាទៅវិញទៅមក។ ទាំងនេះណែនាំឲ្យយើងរកឃើញសេចក្តីសុខ។



*អ្នកជាប់ទោសទទួលអំណោយពីព្រះសហគមន៍ រូបភាពៈ លី សុវណ្ណា*

លោកអភិបាលបានជូនពរបងប្អូនទាំងអស់បានចម្រើនក្នុងព្រះពរ ចម្រើនក្នុងសីលធម៌ ចម្រើនក្នុងសេចក្តីថ្លៃថ្នូរ សេចក្តីសុខ នឹកឃើញជីវិតមានតម្លៃ ដែលបងប្អូនត្រូវទទួលខុសត្រូវ គ្រប់គ្រងគ្រួសារ គ្រប់គ្រងសង្គម គ្រប់គ្រងធម្មជាតិ និងសូមឲ្យបងប្អូនមានកំលាំងថែមទៀតក្នុងការតស៊ូ កែប្រែចិត្តគំនិត។

បន្ទាប់ពិធីសំណេះសំណាលរួចមក គណៈប្រតិភូទាំងអស់ មានលោកអភិបាល ព្រះគ្រូមេគុណខេត្ត ព្រះសង្ឃ ប្រធានគណៈអ៊ីម៉ាំខេត្ត គ្រូគង្វាល និងលោកបូជាចារ្យបានធ្វើពិធីប្រោះព្រំ និងអធិដ្ឋានសម្រាប់បងប្អូនទាំងអស់ឲ្យមានកំលាំងតស៊ូ និង មានសុខភាពល្អ។ រួចមកក៏បានចែកម្ហូបអាហារ តាមបន្ទប់ឃុំឃាំងនីមួយៗដល់បងប្អូនទាំងអស់។

ក្រោយពីពិធីសំណេះសំណាល និងចែករំលែកសេចក្តីស្រលាញ់ដល់បងប្អូនជាប់ឃុំរួចមក ប្រតិភូរួមជាមួយព្រះសង្ឃ បាននិមន្តនិងអញ្ជើញឆាន់ និងទទួលអាហារសាមគ្គីនៅព្រះសហគមន៍កាតូលិកខេត្តកំពត៕

# រដូវអប់រំពិសេស២០២០
## បេក្ខជនចំនួន១៧១នាក់ទទួលការត្រាស់ហៅ







ក្នុងរដូវអប់រំពិសេសឆ្នាំ២០២០នេះ លោកអភិបាលនៃព្រះសហគមន៍កាតូលិកនៅកម្ពុជានៅភូមិភាគទាំងបី បានទទួលស្វាគមន៍ និងត្រាស់ហៅបេក្ខជនចំនួន១៧១នាក់ រួមមាន ភូមិភាគកំពង់ចាមមានចំនួន៤០នាក់ បាត់ដំបងមាន៦១នាក់ និងភ្នំពេញមាន៧០នាក់។ បេក្ខជនទាំងអស់នឹងទទួលពិធីជ្រមុជទឹក(ឬអគ្គសញ្ញាជ្រមុជទឹក)ក្លាយជាគ្រីស្តបរិស័ទកាតូលិកនារាត្រីបុណ្យចម្លងក្នុងខែមេសាខាងមុខនេះ៕







RADIO VERITAS ASIA
# វិទ្យុវេរីតាស់អាស៊ីខេមរភាសា
សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយវិទ្យុ FM នៅភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

លោកអ្នកអាចស្តាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ khmer.rvasia.org និង www.catholiccambodia.org
ឬលោកអ្នកអាច Follow @RVAkhmer ផ្លូវការរបស់យើងតាមរយៈ www.facebook.com/RVAKHMER/
និងតាមដានវីដេអូលើបណ្តាញ Youtube: www.youtube.com/RVAkhmer